ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍បូកសរុបលទ្ធផលការងារ
# អាជ្ញាធរទន្លេសាប
# ប្រចាំឆ្នាំ២០២៤ និងទិសដៅអនុវត្តឆ្នាំ២០២៥



ខែ កុម្ភៈ ឆ្នាំ ២០២៥

# មាតិកា

១. សេចក្តីផ្តើម ........ II
២. ចក្ខុវិស័យ បេសកកម្ម និងតួនាទីភារកិច្ចអាជ្ញាធរទន្លេសាប ........ ២
៣. ផែនការយុទ្ធសាស្ត្រ អាជ្ញាធរទន្លេសាប ........ ៣
៣.១ ផែនការយុទ្ធសាស្ត្រ អាជ្ញាធរទន្លេសាប ២០២៤-២០២៨ ........ ៣
៣.២ ផែនការសកម្មភាពអគ្គលេខាធិការដ្ឋានអាជ្ញាធរទន្លេសាប ២០២៤ ........ ៤
៣.៣ ផែនការសកម្មភាពអគ្គលេខាធិការដ្ឋានអាជ្ញាធរទន្លេសាប ២០២៥ ........ ៤
៤. វឌ្ឍនភាពការងារ និងលទ្ធផលសម្រេចបានក្នុងឆ្នាំ ២០២៤ ........ ៥
៤.១ លទ្ធផលការងារ ........ ៥
៤.១.១ ការងាររដ្ឋបាល បុគ្គលិក និងហិរញ្ញវត្ថុ ........ ៥
ក. ការងាររដ្ឋបាល ........ ៥
ខ. ការងារគ្រប់គ្រងបុគ្គលិក និងបណ្តុះបណ្តាល ........ ៥
គ. ការងារបណ្តុះបណ្តាល ក្នុង និងក្រៅប្រទេស ........ ៦
ឃ. ការងារគ្រប់គ្រងហិរញ្ញវត្ថុ ........ ៧
៤.១.២ ការងារកិច្ចសហប្រតិបត្តិការ ........ ៨
ក. កិច្ចប្រជុំពិគ្រោះយោបល់ក្នុងប្រទេស ........ ៨
ខ. កិច្ចប្រជុំពិគ្រោះយោបល់ក្រៅប្រទេស ........ ១០
៤.១.៣ គម្រោងគ្រប់គ្រងធនធានទឹកចម្រុះអាងស្ទឹងសែន ........ ១៣
៤.១.៤ គម្រោងការតាមដានផលចាប់នៅខេត្តជុំវិញបឹងទន្លេសាប គាំទ្រថវិកាដោយគណៈកម្មការទន្លេមេគង្គតាមរយៈគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា ........ ១៤
៤.១.៥ គម្រោងសិក្សាគំរូបច្ចេកវិទ្យា សង្កេត និងបញ្ជូនទិន្នន័យជលសាស្ត្រសម្រាប់អាងទន្លេសាប កម្ពុជា គាំទ្រថវិកាក្រោមគម្រោងឡាងឆាង-មេគង្គ ........ ១៥
៤.១.៦ ការងារបច្ចេកទេសសិក្សាស្រាវជ្រាវ ........ ១៦
៤.១.៧ ការងារគ្រប់គ្រងសេវាកម្មបច្ចេកវិទ្យាព័ត៌មាន ........ ១៧
ក. ការងារគ្រប់គ្រងសេវាកម្មបច្ចេកវិទ្យាព័ត៌មាន ........ ១៧
ខ. ការងារគ្រប់គ្រង និងផ្សព្វផ្សាយព័ត៌មាន ........ ១៨
៤.២ ការងារចំពោះមុខ ........ ១៩
៤.២.១ ការងារបច្ចុប្បន្នភាពផែនទី និងការបោះបង្គោលព្រំតំបន់៣ ........ ១៩
ក. មូលដ្ឋាននៃការប្រមូលទិន្នន័យ ........ ១៩

ខ. ការងារសាងសង់បង្គោលព្រំតំបន់៣ ........ ២០
គ. ការងារអធិការកិច្ចដែនព្រៃលិចទឹក និងព្រៃលិចទឹក ........ ២១
ឃ. ការងារផ្សព្វផ្សាយច្បាប់បទដ្ឋានគតិយុត្តពាក់ព័ន្ធកិច្ចការពារព្រៃលិចទឹក ........ ២១
**៤.៣ ការវិភាគមុខងារ និងរចនាសម្ព័ន្ធស្ថាប័ន** ........ ២២
**៥. បញ្ហាប្រឈម** ........ ២២
**៦. សន្និដ្ឋាន និងទិសដៅការងារបន្ត** ........ ២៣

## ១. សេចក្តីផ្តើម

អាជ្ញាធរទន្លេសាប គឺជាស្ថាប័នមួយដើរតួនាទីជាសេនាធិការឱ្យរាជរដ្ឋាភិបាល ដែលត្រូវបានបង្កើតឡើងតាមរយៈព្រះរាជក្រឹត្យលេខ នស/រកត/០៦០៩/៧០៥ ចុះថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០០៩ និងបានកែសម្រួលតាមព្រះរាជក្រឹត្យលេខ នស/រកត/០៣១០/២៥៨ ចុះថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១០ ស្តីពីការកែសម្រួលមាត្រា ៣ មាត្រា ៥ មាត្រា ៦ មាត្រា ៩ មាត្រា ១០ និងមាត្រា ១២ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៦០៩/៧០៥ ចុះថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០០៩។ រាជរដ្ឋាភិបាលកម្ពុជាក្នុងនីតិកាលទី៧ នៃរដ្ឋសភា ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់បំផុតរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បានដាក់ចេញនូវគោលនយោបាយ និងជំរុញការអនុវត្ត "យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១" ដើម្បី កំណើន ការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព និងការកសាងមូលដ្ឋានគ្រឹះដ៏រឹងមាំសម្រាប់បន្តដំណើរឈានទៅសម្រេចបាននូវចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០ ក៏ដូចជាការបន្តពង្រឹងសមត្ថភាព អភិបាលកិច្ច និងគុណភាពរបស់ស្ថាប័ន រួមជាមួយការធានាចីរភាពនៃការអភិវឌ្ឍសេដ្ឋកិច្ចសង្គម ការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន ឱ្យឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ។

ការចូលរួមលើកកម្ពស់ប្រសិទ្ធភាពការអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រខាងលើនេះ អាជ្ញាធរទន្លេសាបបានជំរុញការយកចិត្តទុកដាក់ដោយហ្មត់ចត់ ក្នុងស្មារតីពង្រឹងនូវបេសកកម្មការងារ តួនាទី និងភារកិច្ច ការទទួលខុសត្រូវក្នុងនាមជាសេនាធិការផ្ទាល់ឱ្យរាជរដ្ឋាភិបាល លើការសម្របសម្រួលក្នុងការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍តំបន់ទន្លេសាប។ រាជរដ្ឋាភិបាលកម្ពុជា ក៏បានផ្តោតការយកចិត្តទុកដាក់យ៉ាងខ្លាំង ក្នុងការដាក់ចេញនូវវិធានការការពារ ថែរក្សា និងទប់ស្កាត់រាល់បទល្មើសដែលធ្វើឱ្យបាត់បង់ធនធានធម្មជាតិ បរិស្ថាន និងប្រព័ន្ធអេកូឡូស៊ីនៅក្នុងតំបន់បឹងទន្លេសាប រួមជាមួយការធ្វើកំណែទម្រង់ច្បាប់ លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ និងការដាក់ឱ្យអនុវត្តនូវគោលនយោបាយ និងយុទ្ធសាស្ត្រប្រកបដោយភាពម៉ឺងម៉ាត់ និងហ្មត់ចត់ គឺសំដៅជំរុញការងារគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍ធនធានធម្មជាតិ និងបរិស្ថានប្រកបដោយប្រសិទ្ធភាពខ្ពស់។

ក្នុងការបំពេញតួនាទីភារកិច្ច និងការទទួលខុសត្រូវជាមួយនឹងការកំណត់បាននូវកម្មវិធីបេសកកម្មការងារស្នូលរបស់ស្ថាប័ន (១). លើកកម្ពស់កម្មវិធីអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច ដើម្បីលើកកម្ពស់សុខុមាលភាពសង្គម និងប្រជាជននៅតំបន់ជុំវិញបឹងទន្លេសាប និងតំបន់ពាក់ព័ន្ធ (២). លើកកម្ពស់កិច្ចការការពារ និងថែរក្សាធនធានធម្មជាតិ និងបរិស្ថាន ដើម្បីធានាដល់គុណភាពធនធានធម្មជាតិ និងបរិស្ថាន និង(៣). សម្របសម្រួលរាល់គម្រោងដែលបាន និងកំពុងអនុវត្តនៅតំបន់ជុំវិញបឹងទន្លេសាប និងតំបន់ពាក់ព័ន្ធ។ អាជ្ញាធរទន្លេសាប បាននូវកំណត់ចក្ខុវិស័យ គោលដៅ និងទិសដៅយុទ្ធសាស្ត្ររបស់ស្ថាប័ននៅក្នុងផែនការយុទ្ធសាស្ត្ររយៈពេល៥ឆ្នាំ និងយកចិត្តទុកដាក់ពង្រឹងការអនុវត្តរាល់សកម្មភាពជាយុទ្ធសាស្ត្រ ដែលបានកំណត់ក្នុងផែនការយុទ្ធសាស្ត្រ ២០២៤-២០២៨ និងបានដាក់ចេញនូវសកម្មភាពការងារលម្អិតប្រចាំឆ្នាំក្នុងផែនការសកម្មភាពរបស់អគ្គលេខាធិការដ្ឋាន អាជ្ញាធរទន្លេសាប ក្នុងការជំរុញប្រសិទ្ធភាពការងាររបស់ស្ថាប័ន និងចូលរួមលើកកម្ពស់ប្រសិទ្ធភាពការអនុវត្តគោលនយោបាយយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ របស់រាជរដ្ឋាភិបាល។

## ២. ចក្ខុវិស័យ បេសកកម្ម និងតួនាទីភារកិច្ចអាជ្ញាធរទន្លេសាប

អាជ្ញាធរទន្លេសាប គឺជាស្ថាប័នមួយដើរតួនាទីជាសេនាធិការឱ្យរាជរដ្ឋាភិបាល ក្នុងចំណោមបណ្តាក្រសួង-ស្ថាប័នដែលជាសមាជិកត្រូវបានបង្កើតឡើងតាមព្រះរាជក្រឹត្យលេខ នស/រកត/០៦០៩/៧០៥ ចុះថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០០៩ និងបានកែសម្រួលតាមព្រះរាជក្រឹត្យលេខ នស/រកត/០៣១០/២៥៨ ចុះថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១០ ស្តីពីការកែសម្រួលមាត្រា ៣ មាត្រា ៥ មាត្រា ៦ មាត្រា ៩ មាត្រា ១០ និងមាត្រា ១២ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៦០៩/៧០៥ ចុះថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០០៩។

- អាណត្តិការងាររបស់អាជ្ញាធរទន្លេសាប "សម្របសម្រួល ក្នុងការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍តំបន់ទន្លេសាប" ដែលអាណត្តិការងារ ក៏បានបញ្ជាក់ពីការងារជាអាទិភាព គឺផ្តោតលើ ៖
- សម្របសម្រួលរាល់សកម្មភាពមកលើធនធានធម្មជាតិ ការពារ និងថែរក្សាបរិស្ថាន និងជីវរូបសាស្ត្រនៃបឹងទន្លេសាប
- សម្របសម្រួលរាល់កម្មវិធី និងសកម្មភាពសង្គមកិច្ច សេដ្ឋកិច្ច រួមជាមួយនឹងទិសដៅកាត់បន្ថយភាពក្រីក្រនៅតំបន់ទន្លេសាប និងលើកកម្ពស់ការទ្រទ្រង់ជីវភាពរស់នៅរបស់ប្រជាជន




ជាមួយនឹងខ្លឹមសាររបស់ព្រះរាជក្រឹត្យ បង្កើតអាជ្ញាធរទន្លេសាប បានកំណត់ច្បាស់ពីតួនាទីចម្បងរបស់អាជ្ញាធរទន្លេសាប គឺពង្រឹងនូវការសម្របសម្រួលនៅតំបន់ទន្លេសាប ដោយតាមដានត្រួតពិនិត្យ និងវាយតម្លៃ នូវរាល់គម្រោង និងសកម្មភាពនានា ។ ដោយយោងមាត្រាទី ៤ ក៏ដូចជាមានចែងនៅក្នុងលេខាធិការដ្ឋានផងដែរ អាជ្ញាធរទន្លេសាប នឹងមានតួនាទីដោយផ្តោតទៅនឹងគម្រោង ដូចខាងក្រោម ៖

**01** ជាស្ថាប័នសិក្សាស្រាវជ្រាវ តាមដាន និងវាយតម្លៃ អំពីសក្តានុពល សេដ្ឋកិច្ច សង្គមកិច្ច និងធនធានធម្មជាតិនៅតំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធ ដើម្បីរៀបចំផែនការមេ ទស្សនវិស័យ គោលនយោបាយយុទ្ធសាស្ត្រ សម្រាប់ដាក់ជូនរាជរដ្ឋាភិបាល ពិនិត្យ និងសម្រេច

**02** ជាដៃគូ ជួយសម្របសម្រួលក្នុងដំណើរការគម្រោង ដែលគួរបន្តអនុវត្តក្នុងតំបន់ទន្លេសាប

**03** តាមដានត្រួតពិនិត្យការអនុវត្តន៍គម្រោងកំពុងអនុវត្ត ដើម្បីធានាការអនុវត្តបានបំពេញទៅដល់ទិសដៅ និងកម្មវិធីនៃការអនុវត្ត

**04** វាយតម្លៃការអនុវត្តគម្រោង ដែលត្រូវបានបញ្ចប់ ដើម្បីពិនិត្យពីភាពជោគជ័យរបស់គម្រោងជាមួយនឹងគោលដៅដែលចង់បាន

## ៣. ផែនការយុទ្ធសាស្ត្រ អាជ្ញាធរទន្លេសាប

### ៣.១ ផែនការយុទ្ធសាស្ត្រ អាជ្ញាធរទន្លេសាប ២០២៤-២០២៨

ការកំណត់បាននូវក្របខ័ណ្ឌស្នូលនៃផែនការយុទ្ធសាស្ត្ររបស់អាជ្ញាធរទន្លេសាប ត្រូវបានផ្តួចផ្តើមគំនិតក្នុងការរៀបចំឡើង ដោយការប្រមូលផ្តុំរាល់គំនិតយោបល់ ដែលជាធាតុចូលយ៉ាងសំខាន់ៗ ពីកម្រិតថ្នាក់ដឹកនាំ និងមន្ត្រីបច្ចេកទេសពាក់ព័ន្ធ និងបានទទួលការឯកភាពដោយអាជ្ញាធរទន្លេសាប ដើម្បីអោយស្របជាមួយតួនាទីភារកិច្ច និងការទទួលខុសត្រូវដូចបានកំណត់នៅក្នុងបទដ្ឋានគតិយុត្តនៃការបង្កើតអាជ្ញាធរទន្លេសាប ។ ជាពិសេសក្នុងស្មារតីយកចិត្តទុកដាក់ និងចូលរួមគាំទ្រដល់ដំណើរការអនុវត្តកម្មវិធីគោលនយោបាយរបស់រាជរដ្ឋាភិបាលអាណត្តិទី៧ ឱ្យមានប្រសិទ្ធភាព និងប្រសិទ្ធផល ដែលបានកំណត់ និងដាក់ចេញឱ្យអនុវត្តក្នុងគោលនយោបាយយុទ្ធសាស្ត្រ បញ្ចកោណដំណាក់កាលទី ១ ។




១. អភិវឌ្ឍន៍ព័ត៌មាន និងទិន្នន័យឲ្យកាន់តែប្រសើរឡើង អំពីតំបន់បឹងទន្លេសាប និងតំបន់ពាក់ព័ន្ធ

២. លើកកម្ពស់ការយល់ដឹង អប់រំ ផ្សព្វផ្សាយ និងបណ្តុះបណ្តាល

៣. ពង្រឹងភាពជាដៃគូ និងកិច្ចសហប្រតិបត្តិការ ជាមួយដៃគូពាក់ព័ន្ធរបស់អាជ្ញាធរទន្លេសាប

៤. លើលកម្ពស់សមត្ថភាព និងពង្រឹងការគ្រប់គ្រងស្ថាប័នរបស់អាជ្ញាធរទន្លេសាប និងក្រសួង/ស្ថាប័នពាក់ព័ន្ធ

៥. លើកកម្ពស់ និងអភិវឌ្ឍន៍ ការគ្រប់គ្រងបច្ចេកវិទ្យាព័ត៌មានឌីជីថល។

## ៣.២ ផែនការសកម្មភាពអគ្គលេខាធិការដ្ឋានអាជ្ញាធរទន្លេសាប ២០២៤




ផែនការសកម្មភាពការងារឆ្នាំ២០២៤ របស់អាជ្ញាធរទន្លេសាប គឺជា សកម្មភាពការងារលម្អិតសម្រាប់ប្រតិបត្តិការការងារជាក់ស្តែង ដោយមានការចូលរួមសហការពីបណ្តាក្រសួង-ស្ថាប័នទាំងក្នុងកម្រិតថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ ថ្នាក់តំបន់ សង្គមស៊ីវិល អង្គការជាតិ-អន្តរជាតិ និងដៃគូអភិវឌ្ឍន៍នានា ដើម្បីជម្រុញប្រសិទ្ធភាពនៃការអនុវត្តផែនការយុទ្ធសាស្ត្រអាជ្ញាធរទន្លេសាបរយៈពេល ៥ឆ្នាំ (២០២៤-២០២៨) ឱ្យទទួលបានជោគជ័យ។

ជារួម ផែនការសកម្មភាពការងារត្រូវបានរៀបចំឡើងដោយបន្សុីជាមួយ គម្រោងសកម្មភាពការងារអាទិភាពសំខាន់ៗ នៃផែនការយុទ្ធសាស្ត្ររយៈពេល ៥ឆ្នាំ របស់អាជ្ញាធរទន្លេសាប(២០២៤-២០២៨) ។ ជាពិសេសស្របទៅតាមតួនាទីភារកិច្ចការងារទទួលខុសត្រូវ ដូចបានកំណត់ក្នុងអនុក្រឹត្យ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប ដើម្បីពង្រឹងប្រសិទ្ធភាពការងារ និងគាំទ្រដល់បេសកកម្មការងារ ។

## ៣.៣ ផែនការសកម្មភាពអគ្គលេខាធិការដ្ឋានអាជ្ញាធរទន្លេសាប ២០២៥




ផ្អែកលើសមិទ្ធផលនៃការអនុវត្តផែនការសកម្មភាពប្រចាំឆ្នាំ ២០២៤ កន្លងមកអាជ្ញាធរទន្លេសាប បានធ្វើការវាយតម្លៃដោយយកចិត្តទុកដាក់បំផុតលើភាពខ្លាំង និងបញ្ហាប្រឈម ដែលតម្រូវឱ្យបន្តដោះស្រាយដោយភាពហ្មត់ចត់ នៅដំណាក់កាលបន្ទាប់ក្នុងការរៀបចំ និងការអនុវត្តផែនការសកម្មភាពឆ្នាំ ២០២៥ របស់អគ្គលេខាធិការដ្ឋានអាជ្ញាធរទន្លេសាប ដោយអនុលោម តាមស្មារតីនៃបេសកកម្មការងារក្នុងការសម្របសម្រួល ដល់ការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍ តំបន់ទន្លេសាបប្រកបដោយចីរភាព។ ជាពិសេសចូលរួម លើកកម្ពស់ប្រសិទ្ធភាពការអនុវត្តយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាលក្នុងអាណត្តិទី៧ ដើម្បីកំណើន ការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព សំដៅការពារ ថែរក្សា និងពូនជ្រុំសមិទ្ធផលជាតិ លើកកម្ពស់កិត្យានុភាពជាតិឱ្យខ្ពស់ត្រដែត ជម្រុញសន្ទុះនៃកំណើនសេដ្ឋកិច្ច និងកសាង មូលដ្ឋានគ្រឹះឆ្ពោះទៅសម្រេចបាន ចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០។ ផែនការសកម្មភាពការងារឆ្នាំ២០២៥ មានចំនួន ២២សកម្មភាព ដែលសកម្មភាពទាំងនោះ ស្ថិតក្នុងសកម្មភាពយុទ្ធសាស្ត្រ ទិសដៅយុទ្ធសាស្ត្រ និងគោលដៅយុទ្ធសាស្ត្រ នៃផែនការយុទ្ធសាស្ត្រអាជ្ញាធរទន្លេសាបរយៈពេល៥ឆ្នាំ (២០២៤-២០២៨)។

# ៤. វឌ្ឍនភាពការងារ និងលទ្ធផលសម្រេចបានក្នុងឆ្នាំ ២០២៤

## ៤.១ លទ្ធផលការងារ

### ៤.១.១ ការងាររដ្ឋបាល បុគ្គលិក និងហិរញ្ញវត្ថុ

**ក. ការងាររដ្ឋបាល**

- ទទួលបានលិខិតចូលចំនួន១៥៤ច្បាប់ លិខិតចូលផ្ទៃក្នុង ៧៩៥ច្បាប់ លិខិតចេញចំនួន ៦៤៦ច្បាប់ លិខិតចេញផ្ទៃក្នុងចំនួន ១១៣ច្បាប់
- រៀបចំតាក់តែងលិខិតរដ្ឋបាល សម្របសម្រួលសេវារដ្ឋបាល និងកិច្ចការរដ្ឋបាលប្រចាំថ្ងៃក្នុងអង្គភាព
- បានសរុបរបាយការណ៍រួមរបស់ អ.ទ.ស ប្រចាំខេក្នុងឆមាសទី១ ឆ្នាំ២០២៤ និងទិសដៅអនុវត្តបន្ត
- បានសហការរៀបចំកិច្ចប្រជុំបានចំនួន ៤១ លើក
- បានរៀបចំសម្របសម្រួលកិច្ចប្រជុំនានា សិក្ខាសាលា វគ្គបណ្តុះបណ្តាលផ្សេងនៅក្នុងអង្គភាព
- បានរៀបចំ និងរក្សាទុកនូវរាល់ឯកសារ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗ ទាក់ទងនឹង អ.ទ.ស
- បានគ្រប់គ្រង ថែទាំ និងជួសជុលបណ្តាញទឹក ភ្លើង អ៊ីនធឺណែត ម៉ាស៊ីន Printer Copy ជាប្រចាំ
- បានចាត់ចែងការងារ សន្តិសុខ សណ្តាប់ធ្នាប់ និងអនាម័យក្នុងបរិវេណអង្គភាពជាប្រចាំ
- បានរៀបចំផ្គត់ផ្គង់ទឹកបរិសុទ្ធ និងភេសជ្ជៈ ប្រចាំខែ ជូនថ្នាក់ដឹកនាំ និងនាយកដ្ឋានទាំង៤ ក្រោមឱវាទអគ្គលេខាធិការដ្ឋាន អាជ្ញាធរទន្លេសាប
- បានសម្របសម្រួលនូវរាល់ឯកសារពាក់ព័ន្ធ ជូនថ្នាក់ដឹកនាំ និងមន្ត្រីនៅអគ្គលេខាធិការដ្ឋានអាជ្ញាធរទន្លេសាប និងក្រសួង/ស្ថានប័នពាក់ព័ន្ធ
- បានរៀបចំ ថែទាំ និងជួសជុលរថយន្តដែលប្រើប្រាស់នៅអាជ្ញាធរទន្លេសាបជាប្រចាំ
- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលប្រធាននាយកដ្ឋាន និងថ្នាក់ដឹកនាំប្រគល់ជូន។

**ខ. ការងារគ្រប់គ្រងបុគ្គលិក និងបណ្តុះបណ្តាល**

- ឆ្នាំ២០២៤នេះ ថ្នាក់ដឹកនាំ និងមន្ត្រីរាជការដែលបម្រើការងារនៅអគ្គលេខាធិការដ្ឋាន អាជ្ញាធរទន្លេសាបសរុបចំនួន១០០ រូប (ស្រី ១៤ រូប) និងមន្ត្រីជាប់កិច្ចសន្យាចំនួន ២៩រូប(ស្រី ០៥ រូប)
- បានរៀបចំបូកសរុបបញ្ជីវត្តមានប្រចាំខែរបស់ការិ.បុគ្គលិក និងបណ្តុះបណ្តាល
- បានបូកសរុបស្ថិតិ មន្ត្រីរាជការ អទស
- បានរៀបចំបូកសរុបបញ្ជីវត្តមានប្រចាំខែរបស់អគ្គលេខាធិការដ្ឋាន អទស ផ្ញើជូនក្រសួងធនធានទឹក និងឧតុនិយម និងក្រសួងមុខងារសាធារណៈ
- បានរៀបសំណុំឯកសារស្តីពីការបន្តប្រើប្រាស់ និងជ្រើសរើសមន្ត្រីជាប់កិច្ចសន្យា សម្រាប់ អទស ចំនួន ២៩នាក់ ក្នុងឆ្នាំ២០២៤

- បានទទួលរៀបចំដំឡើងថ្នាក់តាមវេនអតីតភាពការងាររបស់មន្ត្រីរាជការ អទស ជូនទៅក្រសួងមុខងារសារធារណៈ ចំនួន ២៤នាក់
- បានរៀបចំសំណុំឯកសារសម្រាកលំហែមាតុភាព ជូនលោកស្រី ចាន់ លក្ខិណា អនុប្រធានការិយាល័យគណនេយ្យ និងហិរញ្ញវត្ថុ
- បានទទួល និងចែកអាំងស៊ីញជូនថ្នាក់ដឹកនាំ និងមន្ត្រី អទស ចំនួន ១០១ រូប
- បានរៀបសំណុំឯកសារ ស្តីពីការស្នើសុំមេដាយការងារជូនថ្នាក់ដឹកនាំ និងមន្ត្រី អទស ចំនួន៦២រូប
- បានរៀបចំឯកសារពាក់ព័ន្ធ ដើម្បីធ្វើប្រកាសលុបឈ្មោះមន្ត្រីរាជការ អទស ចំនួន ០១រូប ដែលបានទទួលមរណៈភាព នាថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២៤
- កំពុងធ្វើបច្ចុប្បន្នភាពបញ្ចូលទិន្នន័យប្រវត្តិរូបមន្ត្រីរាជការ របស់អាជ្ញាធរទន្លេសាប ក្នុងប្រព័ន្ធ HR MIS តាមការណែនាំរបស់ក្រសួងមុខងារសារធារណៈ
- បានរៀបចំប្រកាសស្តីពីការកែសម្រួលសមាសភាពមន្ត្រីជាប់កិច្ចសន្យា អ.ទ.ស ចំនួន ២រូប
- បានរៀបចំបញ្ជូនឈ្មោះ មន្ត្រីរាជការ អ.ទ.ស ទៅក្រសួង ធ.ទ.ឱ ដើម្បីស្នើសុំធ្វើប័ណ្ណសមាជិក ប.ស.ស
- ជូនសហព័ទ្ធ និងកូនក្នុងបន្ទុក
- បានរៀបចំសំណុំឯកសារ សេចក្តីសម្រេច ស្តីពីការដាក់មន្ត្រីរាជការស៊ីវិលឱ្យស្ថិតនៅភាពទំនេរពីមុខងារ របស់កញ្ញា ប្រាក់ ណានីឡែន មន្ត្រី ក្នុងការិយាល័យផែនការ និងសហប្រតិបត្តិការ
- បានរៀបចំសំណុំឯកសារ ប្រកាសស្តីពីការដាក់មន្ត្រីរាជការស៊ីវិលឱ្យស្ថិតនៅភាពទំនេរគ្មានបៀវត្ស របស់លោក សោម សំបូរ អនុប្រធានការិយាល័យអភិរក្ស
- បានរៀបចំសំណុំឯកសារសម្រាកលំហែមាតុភាព ជូនលោកស្រី សុខ សាលីណា អនុប្រធានការិយាល័យធនធានរ៉ែ
- បានទទួលព្រះរាជក្រឹត្យស្តីពីការដំឡើងថ្នាក់ តាមកម្រិតសញ្ញាបត្រ របស់លោកស្រី ទេស សុដាវី
- បានទទួលអនុក្រឹត្យស្តីពីការដំឡើងថ្នាក់ តាមកម្រិតសញ្ញាបត្រ របស់លោកស្រី ប៊ូ សុភ័ស្ត
- បានទទួលប្រកាសស្តីពីការដំឡើងថ្នាក់ តាមកម្រិតសញ្ញាបត្រ របស់លោក ហេង បូរាណ
- បានទទួលលិខិតចូល ៦៩ច្បាប់
- បេសកកម្មចេញក្នុងប្រទេសមានចំនួន ៤៥៥លេខ។

### គ. ការងារបណ្តុះបណ្តាល ក្នុង និងក្រៅប្រទេស

- បានរៀបចុះវគ្គបណ្តុះបណ្តាលជូនដល់មន្ត្រីអាជ្ញាធរទន្លេសាបបានចំនួន ២ វគ្គ ការប្រើប្រាស់ឧបករណ៍ DGPS និង Drone RTK សម្រាប់ជាមូលដ្ឋានដល់មន្ត្រីបច្ចេកទេសអាជ្ញាធរទន្លេសាបចុះអនុវត្តសកម្មភាពកំណត់និយាមកាក្នុងតំបន់២ នាពេលខាងមុខ។







- បានសម្របសម្រួលមន្ត្រី អាជ្ញាធរទន្លេសាបចូលរួមសិក្ខាសាលាវគ្គបណ្តុះបណ្តាលក្នុងប្រទេសចំនួន ២៦លើក និងក្រៅប្រទេសចំនួន ៩ លើក ទៅប្រទេសជប៉ុន ចិន វៀតណាម ថៃ និងប្រទេសឡាវ ។






## ឃ. ការងារគ្រប់គ្រងហិរញ្ញវត្ថុ

- បានអនុវត្តនីតិវិធីកិច្ចលទ្ធកម្មចប់ជាស្ថាពរចំនួន ១០គម្រោង (ទំនិញ៧ សំណង់២ សេវាកម្ម១)
- បានចូលរួមសិក្ខាសាលាពិគ្រោះយោបល់តិវិធីអនុវត្តកិច្ចលទ្ធកម្មសាធារណៈ (ព្រៀងអនុក្រឹត្រ ប្រកាស...)
- បានរៀបចំរបាយការណ៍អនុវត្តកិច្ចលទ្ធកម្មប្រចាំត្រីមាស ឆមាស របាយការណ៍ប៉ានស្មានប្រចាំឆ្នាំ និងបានផ្ញើជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានរៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំ២០២៥ និងបានដាក់ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុអនុម័តរួចរាល់
- បានរៀបចំផែនការថវិកាឆ្នាំ និងវិភាជតាមមុខសញ្ញាចំណាយនីមួយៗ
- បានផ្គត់ផ្គង់សម្ភារព័ត៌មាវិទ្យា និងសង្ហារឹម ការិយាល័យ ប្រេងឥន្ទនៈ ជួសជុលថែទាំបណ្តាញ អគារ ដំបូល ចំណត ចាក់សាបទីធ្លា.........
- បានធ្វើបច្ចុប្បន្នភាពបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ និងតារាងប្រៀបធៀបសម្ភារ (កើន ថយ)
- បានរៀបចំឯកសារទូទាត់ចំណាយបន្ទាន់ និងប្រចាំក្នុងអង្គភាព (ទឹក អាហាសម្រន់ កាហ្វេ និងជួសជុលថែទាំផ្សេងៗ..)

- បានទំនាក់ទំនងជាប្រចាំជាមួយក្រសួងធនធានទឹក និងឧតុនិយម ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រតនាគារជាតិ និងធនាគារជាតិនៃកម្ពុជា ដើម្បីដំណើការឯកសារ
- បានរៀបចំឯកសារទូទាត់ថ្លៃប្រើប្រាស់សេវាអ៊ីនធើណេត អគ្គិសនី ទឹក ឆ្នាំ ២០២៤
- បានរៀបចំឯកសារទូទាត់ (សក្ខីប័ត្រចំណាយ) រដ្ឋទេយ្យបុរេប្រទានចំនួន ៤ជុំវង្វិល
- បានរៀបចំឯកសារទូទាត់ប្រាក់បេសកកម្មចំនួន ៦លើក និងរៀបចំប្រាក់បេសកកម្មបង្វែរត្រង់ចូលគណនីបៀវត្សរបស់មន្ត្រីរាជការ អទស តាមប្រព័ន្ធធនាគារ
- បានរៀបចំរបាយការណ៍ និងកិច្ចបញ្ជិការគណនេយ្យ និងផ្ញើជូនអគ្គនាយកដ្ឋានរតនាគារជាតិ (ប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ)
- បានសហការ និងរៀបចំកសាងឯកសារគម្រោងថវិកាឆ្នាំ ២០២៥ (ទាំងកម្រិតបច្ចេកទេស និងកម្រិតថ្នាក់ដឹកនាំ)
- បានរៀបចំរបាយការណ៍ចំណូល-ចំណាយ (ប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ)
- បានចូលរួមវគ្គបណ្តុះបណ្តាលកម្មវិធីកំណែទម្រង់ហិរញ្ញវត្ថុ (នីតិវិធីចំណាយតាមកម្មវិធីថវិកា តុល្យភាពគណនីចំណូល-ចំណាយតាមប្រព័ន្ធ FMIS ចុះប្រតិបត្តិការហិរញ្ញវត្ថុតាមប្រព័ន្ធFMIS......)
- បានអនុវត្តការងារចាំបាច់ផ្សេងៗ មួយចំនួនទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន។

### ៤.១.២ ការងារកិច្ចសហប្រតិបត្តិការ

ក្នុងកិច្ចសហប្រតិបត្តិការមន្ត្រីថ្នាក់ដឹកនាំ និងមន្ត្រីបច្ចេកទេសតំណាងឱ្យអាជ្ញាធរទន្លេសាប បានធ្វើការទំនាក់ទំនង និងទទួលជួបពិភាក្សាការងារសហប្រតិបត្តិការជាមួយបណ្តាក្រសួង-ស្ថាប័នជាតិ និងអន្តរជាតិនានា រួមមាន (World Bank, ADB, USAID, JICA, Mekong-Lancang Cooperation) ក្នុងការចូលរួមសមាហរណកម្មការយល់ដឹង និងចែករំលែកនូវព័ត៌មានទិន្នន័យ បង្ហាញពីលទ្ធផលសកម្មភាពសិក្សាស្រាវជ្រាវរបស់អាជ្ញាធរទន្លេសាប ក្នុងកិច្ចប្រជុំ ប្រឹក្សាយោបល់ ជាពិសេសជាមួយដៃគូគម្រោងពាក់ព័ន្ធដូចជា ៖

#### ក. កិច្ចប្រជុំពិគ្រោះយោបល់ក្នុងប្រទេស





**១.** ចូលរួមកិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់ជាតិ ស្តីពីការសិក្សារួមគ្នាលើបម្រែបម្រួលជលសាស្ត្រក្នុងអាងទន្លេមេគង្គ-ឡានឆាង និងផែនការយុទ្ធសាស្ត្របន្សាំ រៀបចំដោយគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា។

**២.** ចូលលរួមកិច្ចប្រជុំថ្នាក់ជាតិ ស្តីពីការរៀបចំឯកសារគម្រោង ពង្រឹងការគ្រប់គ្រងជលផលឆ្លងដែនក្នុងអាងទន្លេមេគង្គភាគខាងក្រោម។

**៣.** ចូលរួមពិភាក្សា ស្តីពីគម្រោងវាយតម្លៃសេចក្តីត្រូវការ និងការត្រៀមខ្លួន នៃថវិកាអាកាសធាតុបៃតង(Green Climate Fund Readiness Needs Assessment)។

**៤.** បានជួបប្រជុំពិភាក្សាការងារជាមួយតំណាងរដ្ឋបាលជលផល នៃក្រសួង





កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដឹកនាំដោយ លោកបណ្ឌិត ទូច ប៊ុនថង អនុប្រធាន វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ជលផលទឹកសាប។

**៥.** ជួបប្រជុំពិភាក្សាជាមួយ សាស្ត្រាចារ្យបណ្ឌិតនៃវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា និង Dr. Yoshihamura-sensei គម្រោង SATREPs ដើម្បីពិគ្រោះយោបល់ និងផ្លាស់ប្តូរគំនិតទស្សនទាននៃការផ្តួចផ្តើមគំនិតលើកកម្ពស់ការកសាងសមត្ថភាព និងពង្រឹងការសិក្សាស្រាវជ្រាវ ក្នុងកិច្ចសហប្រតិបត្តិការ និងទំនាក់ទំនងរវាង អាជ្ញាធរទន្លេសាប និងវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជាសម្រាប់និរន្តរភាពបឹងទន្លេសាប ។

**៦.** បានអញ្ជើញចូលរួមកិច្ចប្រជុំអន្តរក្រសួង ដើម្បីពិនិត្យ និងពិភាក្សាលើបែបបទនីតិវិធីច្បាប់ ក្នុងការផ្ទេរលេខាធិការដ្ឋានបបនីយជីវមណ្ឌលបឹងទន្លេសាប និងលេខាធិការពី គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា ឱ្យទៅស្ថិតនៅក្នុងរចនាសម្ព័ន្ធ និងការគ្រប់គ្រងរបស់អាជ្ញាធរទន្លេសាប ។

**៧.** បានដឹកនាំដឹកនាំប្រតិភូអន្តរក្រសួង ស្ថាប័នពាក់ព័ន្ធ មន្ត្រីក្រុមការងារបច្ចេកទេសអាជ្ញាធរទន្លេសាប ប្រជុំពិភាក្សាលើការស្នើសុំកំណត់តំបន់ការពារ និងអភិវឌ្ឍន៍ប្រភពទឹក ស្ថិតនៅក្នុងអាង នៃបឹងទន្លេសាប សម្រាប់ផ្គត់ផ្គង់ទឹក ក្នុងក្រុងសៀមរាប និងតំបន់ជុំវិញខេត្តសៀមរាប ។

**៨.** បានចូលរួមកិច្ចប្រជុំស្តីពី ការធ្វើបច្ចុប្បន្នភាពក្របខ័ណ្ឌធារទឹក សម្រាប់នីតិវិធីថែរក្សាទឹកនៅលើទន្លេមេ នៃទន្លេមេគង្គ និងការបញ្ចប់របាយការណ៍មេគង្គប្រចាំឆ្នាំ២០២៣ ផ្នែកជលសាស្ត្រ ទឹកជំនន់ និងភាពរាំងស្ងួត នៅទីរួមខេត្តកំពង់ចាម ។

**៩.** បានដឹកនាំកិច្ចប្រជុំពិភាក្សាលើការចុះពិនិត្យ ផ្ទៀងផ្ទាត់ តាមដាន និងអធិការកិច្ចដែនព្រៃលិចទឹក និងព្រៃលិចទឹកស្ថិតក្នុងភូមិសាស្ត្រខេត្តសៀមរាប។

**១០.** បានជុំពិភាក្សារៀបចំផែនការកសាងផែនទីសណ្ឋានដីបាតបឹងទន្លេសាប និងបាតទន្លេសាប ចាប់ពីតំបន់ទន្លេចតុមុខរហូតដល់បឹងទន្លេសាប ជាមួយប្រធាន អនុប្រនាយដ្ឋានជលសាស្ត្រ និងការងារទន្លេ នៃក្រសួងធនធានទឹកនិងឧតុនិយម និងប្រធានលេខាធិការដ្ឋានបបនីយជីវមណ្ឌលបឹងទន្លេសាបនៃគណៈកម្មការជាតិទន្លេមេគង្គកម្ពុជា ។



**១១.** បានរៀបចំកិច្ចប្រជុំពិគ្រោះយោបល់កម្រិតបច្ចេកទេសអន្តរក្រសួង ស្តីពីការពិនិត្យ និងផ្ទៀងផ្ទាត់ឡើងវិញលើការកំណត់បែងចែកតំបន់ជុំវិញបឹងទន្លេសាប ។



**១២.** បានចូលរួមសិក្ខាសាលាស្តីពីកិច្ចសន្ទនាគោលនយោបាយផ្តោតលើ " ការពង្រឹងការគ្រប់គ្រងធនធានទឹកខ្នាតតូច " សម្រាប់សហគមន៍កសិកម្មតាំងក្រសាំង និងត្រពាំងត្របែកនៃស្ទឹងជ្រៃបាក់ នៅខេត្តកំពង់ឆ្នាំង។

**១៣.** ចូលរួមសិក្ខាសាលាពិគ្រោះយោបល់លើកទី១ ស្តីពីផែនការគ្រប់គ្រងអាងស្ទឹង ជីនិតរបស់គម្រោងកែលម្អប្រព័ន្ធធារាសាស្ត្រកសិកម្ម នៅផ្នែកខាងត្បូងក្រុងស្ទឹងសែនខេត្តកំពង់ធំនៅសណ្ឋាគារកំពង់ធំរ៉ូយ៉ាល់។



**១៤.** ចូលរួមទស្សនកិច្ចឋបនីយជីវមណ្ឌលបឹងទន្លេសាប ព្រែកទាល់ និងកិច្ចពិគ្រោះយោបល់ផែនការយុទ្ធសាស្ត្រ ស្តីពីកិច្ចពិគ្រោះយោបល់ និងប្រមូលធាតុចូលសម្រាប់រៀបចំផែនការយុទ្ធសាស្ត្រឋបនីយជីវមណ្ឌលបឹងទន្លេសាប ២០២៤-២០២៨ ដែលដឹកនាំ និងសម្របសម្រួលដោយ លោកជំទាវ ម៉ុម ថានី រដ្ឋលេខាធិការ ស្ថិតនៅឃុំកោះជីវាំង ស្រុកឯកភ្នំ ខេត្តបាត់ដំបង។

## ខ. កិច្ចប្រជុំពិគ្រោះយោបល់ក្រៅប្រទេស






**១.** បានសន្និសីទអន្តរជាតិ Taihu ស្តីពីការគ្រប់គ្រងទឹកបឹង (InConTaihu) និងទស្សនកិច្ចសិក្សានៅ ក្រុមហ៊ុនផលិតជ្រូន នាទីក្រុង wuxi នៃសាធារណៈរដ្ឋប្រជាមានិតចិន។

**២.** បានចូលរួមវេទិកាមូសុងជាតិលើកទី១០ សហការរៀបចំ និងសម្របសម្រួលដោយក្រសួងធនធានទឹក និងឧតុនិយមគាំទ្រដោយអង្គការឧតុនិយមពិភពលោក WMO និង RIMES ។

**៣.** បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពី ការបន្សាំទៅនឹងប្រព័ន្ធអេកូឡូស៊ី"Eco-system -Based Adaptation" ក្រោមកិច្ចសហការណ៍ និងសម្របសម្រួលដោយ អង្គការ IUCN ប្រចាំប្រទេសថៃ។






**៤.** ពិភាក្សាការងារបង្កើតកិច្ចសហប្រតិបត្តិការ ជាមួយប្រតិភូតំណាងការិយាល័យជលសាស្ត្រនៃគណៈកម្មការធនធានទឹកChangjaing នៃក្រសួងធនធានទឹក សាធារណៈរដ្ឋប្រជាមានិតចិន។

**៥.** បានចូលរួមសិក្ខាសាលាថ្នាក់តំបន់ស្តីពី ការឆ្ពោះទៅរកដំណោះស្រាយយកកម្រិតមូលដ្ឋាន-ការគ្រប់គ្រងធនធានទឹកខ្នាតតូច ក្នុងអនុតំបន់មេគង្គ"Heading Towards Local-Based Solution-Small-Scale Water Resource Management in the Mekong Sub-region" នៅប្រទេសថៃ។

**៦.**បានជួបពិភាក្សាការងារអនុវត្តគម្រោងលើកកម្ពស់ជីវភាពធន់នឹងអាកាសធាតុនៃសហគមន៍ផលិតស្រូវនៅតំបន់បឹងទន្លេសាប(PCRL)ជាមួយលោកបណ្ឌិត ម៉ាស៊ីម៉ូសារទី ទីប្រឹក្សាអន្តរជាតិ អមជាមួយលោក វេន សារុជ ទីប្រឹក្សាជាតិ ផ្នែកវាយតម្លៃភាពងាយ រងគ្រោះ និងហានិភ័យ (VRA) និងការកំណត់តំបន់កសិ-អេកូឡូស៊ី (AEZ) និងលោកបណ្ឌិត ហេង សុខឆាយ សាស្ត្រាចារ្យនៃវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា។

**៧.** បានចូលរួមជាវាគ្មិនតំណាងឱ្យប្រទេសកម្ពុជា និងជាអ្នកសម្របសម្រួលលើប្រធានបទ កិច្ចសហប្រតិបត្តិការឆ្លងដែនរបស់ទន្លេ និងការគ្រប់គ្រងនៃគុណភាពទឹកក្នុងមហាសន្និបាតពិភពលោកស្តីពីការគ្រប់គ្រងអាងទន្លេ (World General Assem-bly on Basin Management) នៅទីក្រុង Bordeaux ប្រទេសបារាំង។

**៨.** បានទៅចូលរួមសិក្ខាសាលាស្តីពី "រួមបញ្ចូលគ្នាលើការគ្រប់គ្រងធនធានទឹក (Integrated Water Resources Man-agement)" នៅទីក្រុង Hangzhou ខេត្ត Zhejiang ទីក្រុង Nanjing ខេត្ត Jiangsu និងទីក្រុង Beijing នៃសាធារណៈរដ្ឋប្រជាមានិតចិន។

**៩.** ចូលរួមវគ្គបណ្តុះបណ្តាលស្តីពី ការគ្រប់គ្រងធនធានទឹកជាក់ស្តែងសម្រាប់ដោះស្រាយបញ្ហាទឹក "Practical IWRM (Integrated Water Resources Management) for Solving Water Problems" ស្ថិតនៅទីក្រុងតូក្យូ (Tokyo) និងទីក្រុងគីតាគូស៊ូ (Kitakyushu) ប្រទេសជប៉ុន។

**១០.** បានដឹកនាំកិច្ចប្រជុំពិភាក្សាលើកទី១ ជាមួយក្រុមការងារបច្ចេកទេសអាជ្ញាធរទន្លេសាប ដើម្បីស្តាប់បទបង្ហាញបច្ចេកទេសការងារ របស់ទីប្រឹក្សាបច្ចេកទេសអន្តរជាតិ ដែលធនាគារពិភពលោកបានជ្រើសរើសឱ្យជួយកិច្ចការបច្ចេកទេសដល់អាជ្ញាធរទន្លេសាប ក្នុងដំណើរការរៀបចំក្របខ័ណ្ឌយុទ្ធសាស្ត្រ សម្រាប់អាងបឹងទន្លេសាប នៃកម្មវិធីការអនុវត្តវាយតម្លៃ សន្តិសុខទឹក ឆ្នាំ២០២៤-២០២៦។

**១១.** ជួបពិភាក្សាក្រុមការងាររៀបចំគម្រោងផែនការ និងស្តាប់ការធ្វើបទបង្ហាញរបស់មន្ត្រីបច្ចេកទេសអាជ្ញាធរទន្លេសាប ស្តីពី "ការសិក្សាអំពីគុណភាពទឹកនៅក្នុងប្រព័ន្ធអេកូហាយដ្រូឡូជីដ៏ស្មុគស្មាញរបស់បឹងទន្លេសាប និងបរិស្ថានជុំវិញ" ដែលចូលរួមប្រឹក្សាយោបល់ដោយ លោកបណ្ឌិត អ៊ុក សុវណ្ណារ៉ា សាស្ត្រាចារ្យ និងអ្នកស្រាវជ្រាវនៅសាកលវិទ្យាល័យអាមេរិចកាំងភ្នំពេញ (AUPP) និង វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា (ITC)។

**១២.** ចូលរួមសិក្ខាសាលាបណ្តុះបណ្តាលស្តីពី ការកសាងសមត្ថភាពនៃកម្មវិធីការគ្រប់គ្រងភាពរាំងស្ងួតចម្រុះ (Inte-grated Drought Management Programme) ខេត្តកែប ។

**១៣.** បានចូលរួមសិក្ខាសាលាស្តីពី "ការពង្រឹងកិច្ចសហប្រតិបត្តិការ ដើម្បីដោះស្រាយផលប៉ះពាល់ នៃការប្រែប្រួលអាកាសធាតុនៅទន្លេមេគង្គក្រោមតាមរយៈការទទួលទិន្នន័យជលសាស្ត្រ និងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ" នៅសាលប្រជុំសាលាខេត្តស្ទឹងត្រែង រៀបចំដោយអង្គការអុកស្វាម និងដៃគូរបស់អុកស្វាម (OXFAM)។






**១៤.** សិក្ខាសាលាស្តីពី " វឌ្ឍនភាពក្នុងការអភិវឌ្ឍន៍ទីផ្សារកាបូនរបស់ប្រទេសចិន និងកិច្ចសហប្រតិបត្តិការទីផ្សារកាបូនសកល (China's Carbon Market De-velopment Progress and Global Market Cooperation Seminar) " នៅទីក្រុង Wuhan ខេត្ត Hubei នៃសាធារណៈរដ្ឋប្រជាមានិតចិន។

**១៥.** រៀបចំឯកសារគម្រោង "ការប្រើប្រាស់បច្ចេកវិទ្យាអង្កេតពីលំហរ ពីទីតាំងភូមិសាស្ត្រ និងស្ថានភាពទំនប់ទឹក និងអាងទឹកក្នុងប្រទេសកម្ពុជា" សិក្ខាសាលាថ្នាក់

ជាតិនេះ រៀបចំដោយធនាគារពិភពលោក(World Bank)។

**១៦.** ចូលរួមកិច្ចប្រជុំក្រុមការងារថ្នាក់ជាតិលើកទី៦ នៃគម្រោងស្ដីពី "ការគ្រប់គ្រងទឹកជំនន់ និងភាពរាំងស្ងួតនៅតំបន់ព្រំដែនកម្ពុជា-ថៃ នៃអនុអាង 9C-9T " ដែលមានការគាំទ្រថវិកាដោយអង្គការ GIZ រួមសហការសម្របសម្រួលដោយ MRC និង CNMC។

**១៧.** រៀបចំឯកសារគម្រោង "ពង្រឹងការគ្រប់គ្រងជលផលឆ្លងដែនក្នុងអាងទន្លេមេគង្គភាគខាងក្រោម" នៅសណ្ឋាគារកាំបូឌីយ៉ាណា ដែលសហការរៀបចំដោយ MRC និង CNMC។

**១៨.** ចូលរួមចែករំលែកការយល់ដឹងលើទស្សនៈវិស័យយុទ្ធសាស្ត្រ របស់អាជ្ញាធរទន្លេសាបក្នុងការគ្រប់គ្រងបឹងទន្លេសាប ក្នុងកិច្ចប្រជុំការអភិវឌ្ឍន៍សមត្ថភាពទិន្នន័យនយោបាយទឹក ក្រោមកម្មវិធីអភិបាលកិច្ចទឹកតំបន់មេគង្គ។

**១៩.** បានដឹកនាំគណៈប្រតិភូធនាគារពិភពលោក លោកស្រី Maria Angelica Sotomayor ចុះពិនិត្យស្វែងយល់ពីស្ថានភាពទូទៅ និងការរស់នៅរបស់ប្រជាពលរដ្ឋភូមិបណ្ដែតទឹកក្នុងតំបន់បឹងទន្លេសាប ស្ថិតក្នុងភូមិសាស្ត្រឃុំកំពង់លួង ស្រុកក្រគរ ខេត្តពោធិ៍សាត់ ។

**២០.** អញ្ជើញចូលរួមកិច្ចប្រជុំអន្តរក្រសួងស្ថាប័ន ពិភាក្សាពាក់ព័ន្ធនឹងឋបនីយជីវមណ្ឌលបឹងទន្លេសាប ស្របតាមការស្នើសុំរបស់គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា។

**២១.** បានចូលរួមសិក្ខាសាលាពិគ្រោះយោបល់ ស្ដីពីការបំពុលប្លាស្ទិកក្នុងទន្លេនៅប្រទេសកម្ពុជា នៅសណ្ឋាគារកាំបូឌីយ៉ាណា រាជធានីភ្នំពេញ ដែលរៀបចំដោយអគ្គនាយកដ្ឋានគាំពារបរិស្ថាន នៃក្រសួងបរិស្ថានជាមួយកម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ (UNEP)។



**២២.** ជួបប្រជុំពិភាក្សាជាមួយភាគីចិនមកពីមជ្ឈមណ្ឌលសហប្រតិបត្តិការធនធានទឹកLancang-Mekong(LMC Water Center) និងក្រុមហ៊ុន SUN Create តាមរយៈប្រព័ន្ធ Zoom Meeting ស្ដីអំពី "គម្រោងប្រព័ន្ធត្រួតពិនិត្យរបាយទឹកភ្លៀង និងប្រព័ន្ធការជូនដំណឹងជាមុន ពីគ្រោះមហន្តរាយអាកាសធាតុ ក្នុងតំបន់អាងទន្លេសាប" ហើយថវិកាគាំទ្រទទួលបានពីមូលនិធិពិសេសនៃកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង។








## ៤.១.៣ គម្រោងគ្រប់គ្រងធនធានទឹកចម្រុះអាងស្ទឹងសែន





ឯកឧត្តម **លឹម ពុឃ** អនុប្រធានអាជ្ញាធរទន្លេសាប និងជាប្រធានក្រុមការងារគម្រោងគ្រប់គ្រងធនធានទឹកចម្រុះនៃអាងស្ទឹងសែន បានអញ្ជើញដឹកនាំកិច្ចប្រជុំប្រចាំឆ្នាំរបស់គណៈកម្មការគ្រប់គ្រងធនធនធានទឹកចម្រុះនៃអាងស្ទឹងសែនឆ្នាំ ២០២៤ រួមជាមួយឯកឧត្តម ស៊ិន វិសិទ្ធ អនុរដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម ឯកឧត្តម ជា សុខនី អគ្គលេខាធិការរងនៃអាជ្ញាធរទន្លេសាប ឯកឧត្តម ព្រឹម វង្ស ប្រធានក្រុមប្រឹក្សាភិបាល និងឯកឧត្តម អ៊ុក គឹមសាន្ត អនុប្រធានក្រុមប្រឹក្សាភិបាលនៃគណៈកម្មការគ្រប់គ្រងធនធានទឹកចម្រុះនៃអាងស្ទឹងសែន សមាជិក សមាជិកានៃក្រុមការងារប្រតិបត្តិគ្រប់គ្រងធនធានទឹកចម្រុះនៃអាងស្ទឹងសែន ព្រមទាំងអង្គការដៃគូរបស់គម្រោងស្ទឹងសែន រួមមានអង្គការក្រៅរដ្ឋាភិបាល បារាំង GESCOD HAMAP GRET និងអង្គការទឹកភ្លៀងកម្ពុជា និងសមាគមទឹកស្អាតអាង ស្ទឹងសែន។ **កិច្ចប្រជុំនេះមានគោលបំណង៖**




- បូកសរុបលទ្ធផលការងារឆ្នាំ ២០២៤ ដោយមានធ្វើបទបង្ហាញ (១) សេចក្តីរាយការណ៍សង្ខេបអំពីការសិក្សា តាមដានរបស់ក្រុមការងារចំនួន ៣ គឺ ផ្នែកទឹកស្អាត និងសុខុមាលភាព, ធនធានទឹក និងកសិកម្ម និង ផ្នែកបរិស្ថាន, (២) វឌ្ឍនភាពដំណើរការរបស់គម្រោង ឆ្នាំ២០២៤ និង សកម្មភាពដែលត្រូវអនុវត្តនៅឆ្នាំ ២០២៥-២០២៦
- វឌ្ឍនភាពរបស់គម្រោងអភិវឌ្ឍន៍ក្នុងការសាងសង់ស្ថានីយផ្គត់ផ្គង់ទឹកស្អាតក្នុងអាងស្ទឹងសែនដែលជាជំនួយឥតចំណងរបស់ទីភ្នាក់ងារទឹក បារាំង Rhin-Meuse និង Loire-Bretagne ដែលទទួលអនុវត្តដោយ អង្គការក្រៅរដ្ឋាភិបាលបារាំង និងសមាគមទឹកស្អាតអាងស្ទឹងសែន ព្រមទាំងបញ្ហាប្រឈម
- បទបង្ហាញស្តីពីគម្រោងកិច្ចការពារតំបន់អភិរក្សបរិស្ថាន និងតំបន់អភិរក្សធនធានត្រីនៃទំនប់អាងទឹករក្សា
- ផ្សព្វផ្សាយ និងប្រគល់សៀវភៅស្តីពីការគ្រប់គ្រងធនធានទឹកចម្រុះនៅព្រះរាជាណាចក្រកម្ពុជា-លើអាងស្ទឹងគម្រូស្ទឹងសែន-បទពិសោធន៍លើកិច្ចសហប្រតិបត្តិការភាពជាដៃគូ រវាងភាគីបារាំងនិងភាគីកម្ពុជារយៈពេល10ឆ្នាំ
- ការបោះឆ្នោតជ្រើសរើសសមាសភាពក្នុងការបង្កើតក្រុមការងារទី ៣ ផ្នែកបរិស្ថាន
- បោះឆ្នោតសម្រេចលើសកម្មភាពដែលត្រូវអនុវត្តនៅឆ្នាំ ២០២៥-២០២៦។

### ៤.១.៤ គម្រោងការតាមដានផលចាប់នៅខេត្តជុំវិញបឹងទន្លេសាប គាំទ្រថវិកាដោយគណៈកម្មការទន្លេមេគង្គ តាមរយៈគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា

អាជ្ញាធរទន្លេសាបបានធ្វើការសិក្សាស្រាវជ្រាវការតាមដានភាពសម្បូរបែប និងនានាភាពនៃប្រភេទត្រីតាមបណ្តាខេត្តជុំវិញ បឹងទន្លេសាបអស់រយៈពេល ១៤ឆ្នាំ កន្លងមកហើយ ដោយមានការជួយគាំទ្រ និងឧបត្ថម្ភថវិកា និងបច្ចេកទេសពីគណៈកម្មការទន្លេមេគង្គ និងសម្របសម្រួលការងារដោយគណៈកម្មការជាតិទន្លេមេគង្គកម្ពុជា។ ក្នុងកិច្ចដំណើរការគម្រោងសិក្សាស្រាវជ្រាវការតាមដានភាពសម្បូរបែប និងនានាភាពនៃប្រភេទត្រីតាមបណ្តាខេត្តជុំវិញបឹងទន្លេសាប អនុវត្តដោយក្រុមការងារនាយកដ្ឋានត្រួតពិនិត្យការធ្វើអាជីវកម្ម និងអភិរក្ស នៃអាជ្ញាធរទន្លេសាប បានចាប់ផ្តើមនៅឆ្នាំ ២០១២ រហូតមកដល់ពេលបច្ចុប្បន្ន។ ការសិក្សានេះមានគោលបំណងសំខាន់ក្នុងការប្រមូលទិន្នន័យផលចាប់របស់អ្នកនេសាទ តាមដានភាពសម្បូរបែប និងនានាភាពរបស់ត្រី ធ្វើបច្ចុប្បន្នភាពមូលដ្ឋានទិន្នន័យជាតិស្ដីពីភាពសម្បូរបែប និងនានាភាពនៃប្រភេទត្រី និងរៀបចំរបាយការណ៍តាមដានដែលពន្យល់ពីស្ថានភាព និងនិន្នាការនៃធនធានជលផលនៅតំបន់បឹងទន្លេសាបនៃប្រទេសកម្ពុជា។

គម្រោងការតាមដានភាពសម្បូរបែប និងនានាភាពនៃប្រភេទត្រីត្រូវបានបង្កើតឡើងដោយផ្អែកលើការស្ទង់មតិវាយតម្លៃការចាប់ត្រីតាមមូលដ្ឋាននៅក្រោមការតាមដានផលចាប់លើវិស័យជលផលមេគង្គ និងកម្មវិធីត្រួតពិនិត្យភាពសម្បូរត្រីក្នុងតំបន់នៃបរិស្ថានជលផល ការវាយតម្លៃ និងសមាសធាតុកាត់បន្ថយ។ ការស្ទង់មតិវាយតម្លៃការចាប់ត្រីត្រូវបានអនុវត្តសម្រាប់រយៈពេលមួយឆ្នាំក្នុងឆ្នាំ ២០០៦ នៅក្នុងប្រទេសកម្ពុជា ឡាវ និង ប្រទេសថៃ ខណៈដែលការតាមដានភាពសម្បូរបែប និងនានាភាពនៃប្រភេទត្រី ត្រូវបានអនុវត្តនៅចន្លោះឆ្នាំ ២០០៧ និង ២០១៤ នៅក្នុងប្រទេសសមាជិកគណៈកម្មការទន្លេមេគង្គចំនួន ៤ ប្រទេស មានប្រទេសកម្ពុជា ឡាវ ថៃ និងប្រទេសវៀតណាម ហើយបន្ទាប់មកបានចាប់ផ្តើមម្តងទៀតនៅឆ្នាំ ២០១៧ រហូតមកដល់បច្ចុប្បន្ន។

ការតាមដានភាពសម្បូរបែប និងនានាភាពនៃប្រភេទត្រីធ្វើការតាមដានលើទីតាំងចំនួន ៣៨ទីតាំង ចាប់ពីខេត្តបកែវ ប្រទេសឡាវ រហូតដល់តំបន់ដីសណ្តរនៃប្រទេសវៀតណាម៖

- ១៥ ទីតាំង នៅតាមដងទន្លេមេគង្គ
- ១២ ទីតាំង នៅតាមដៃទន្លេធំ
- ៨ ទីតាំង នៅតាមវាលទំនាបលិចទឹក
- ២ ទីតាំង នៅជាប់មាត់សមុទ្រ
- ១ ទីតាំង នៅតាមប្រឡាយ។



### ៤.១.៥ គម្រោងសិក្សាគំរូបច្ចេកវិទ្យា សង្កេត និងបញ្ជូនទិន្នន័យជលសាស្ត្រសម្រាប់អាងទន្លេសាប កម្ពុជា គាំទ្រថវិកាក្រោមគម្រោងឡានឆាង-មេគង្គ



អាជ្ញាធរទន្លេសាប បានធ្វើកិច្ចសហការជាមួយវិទ្យាស្ថានស្រាវជ្រាវជលសាស្ត្រ និងស្វ័យប្រវត្តិកម្ម ការអភិរក្សទឹកណានជីង (NIHWA) នៃក្រសួងធនធានទឹកចិន ក្នុងការអនុវត្តគម្រោងសិក្សាគំរូបច្ចេកវិទ្យាសង្កេត និងបញ្ជូនទិន្នន័យជលសាស្ត្រសម្រាប់អាងទន្លេសាប ប្រទេសកម្ពុជា (Pilot Project of Hydrological Data Observation and Transmission Technology for Tonle Sap Basin in Cambodia) ដែលមានចំនួន ១១ ស្ថានីយ លើទីតាំង ៨ កន្លែង សម្រាប់ប្រមូលទិន្នន័យរបបជលសាស្ត្រ និងអាកាសធាតុ នៅតំបន់ជុំវិញ អាងទន្លេសាប ដែលបានចាប់ផ្តើមដំណើរសាងសង់នៅ ខែមករា ឆ្នាំ២០២៣ និងបានបញ្ចប់ការដំឡើងស្ថានីយនៅខែមីនា ឆ្នាំ២០២៣ ។ ស្ថានីយទាំង ១១ រួមមាន៖ ខេត្តកំពង់ធំមាន ៤ស្ថានីយ ខេត្តកំពង់ឆ្នាំង ២ស្ថានីយ ខេត្តពោធិ៍សាត់ ២ស្ថានីយ ខេត្តបាត់ដំបង ២ស្ថានីយ និងខេត្តសៀមរាប ១ស្ថានីយ។





### ៤.១.៦ ការងារបច្ចេកទេសសិក្សាស្រាវជ្រាវ

ក្នុងស្មារតីយកចិត្តទុកដាក់អនុវត្តបេសកកម្មការងារដូចកំណត់ក្នុងច្បាប់បទដ្ឋានគតិយុត្ត និងផែនការយុទ្ធសាស្ត្រឱ្យទទួលបានជោគជ័យតាមគោលដៅ និងទិសដៅរំពឹងទុក អាជ្ញាធរទន្លេសាប បានដាក់ចេញនូវផែនការសកម្មភាពអនុវត្តប្រចាំឆ្នាំ ដោយមានការប្រមូលចងក្រង និងវិភាគព័ត៌មាន ទិន្នន័យ ដែលបានពីការចុះសិក្សាស្រាវជ្រាវ និងស្វែងយល់ជាក់ស្តែងជាច្រើន នៅក្នុងតំបន់បឹងទន្លេសាប និងតំបន់ពាក់ព័ន្ធ ដើម្បីពង្រឹងដល់ការយល់ដឹង តាមរយៈការផ្សព្វផ្សាយ និងចែករំលែកដល់អ្នកធ្វើសេចក្តីសម្រេចចិត្ត អ្នកសិក្សាស្រាវជ្រាវ និងអ្នករៀបចំគោលនយោបាយ កម្មវិធី/គម្រោង ផែនការយុទ្ធសាស្ត្រ។ល។ អំពីការគ្រប់គ្រងតំបន់បឹងទន្លេសាបប្រកបដោយចីរភាព។

សកម្មភាពចុះសិក្សាស្រាវជ្រាវនេះ អាជ្ញាធរទន្លេសាប បានយកចិត្តទុកដាក់ក្នុងការវិភាគចងក្រងនូវរាល់ព័ត៌មានទិន្នន័យពាក់ព័ន្ធ រួមមាន៖

(១). សៀវភៅសកម្មភាពពិនិត្យតាមដានអធិការកិច្ច និងកំណត់ដែនព្រៃលិចទឹក ស្ថិតក្នុងខេត្តទាំង៦ ជុំវិញបឹងទន្លេសាប

(២). សៀវភៅការសិក្សាលើប្រភេទត្រីផ្លាស់ប្តូរទីតាំងពីបឹងទន្លេសាប និងតំបន់ពាក់ព័ន្ធតាមដងទន្លេនៅចុងរដូវវស្សា

(៣). សៀវភៅការសិក្សាលើការវិវត្តព្រៃលិចទឹកតំបន់៣ នៃបឹងទន្លេសាប

(៤). ការសិក្សាស្តីពីរបបជលសាស្ត្រ និងគុណភាពទឹកនៃបឹងទន្លេសាប

(៥). គុណភាពទឹកនៅក្នុងប្រព័ន្ធជីពចរទឹកជំនន់តំបន់ទំនាបត្រូពិច ៖ បឹងទន្លេសាប ប្រទេសកម្ពុជា។





លទ្ធផលការសិក្សាស្រាវជ្រាវឆ្នាំ២០២៤ និងការធ្វើបច្ចុប្បន្នភាព ព័ត៌មានទិន្នន័យដែលមានស្រាប់ បានមកពីប្រភពពាក់ព័ន្ធនានា បានឆ្លុះបញ្ចាំងឱ្យឃើញពីរបកគំហើញក្នុងការប្រែប្រួលបរិយាកាសស្ថានភាព សេដ្ឋកិច្ច សង្គមកិច្ច ធនធានធម្មជាតិ បរិស្ថាន និងដំណើរការគ្រប់គ្រងពីអ្នកពាក់ព័ន្ធដោយផ្ទាល់ និងដោយប្រយោលមកលើការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍតំបន់បឹងទន្លេសាប និងតំបន់ពាក់ព័ន្ធ រួមមាន៖ ធនធានជលផល របបជលសាស្ត្រ ធនធានទឹក ជីវសាស្ត្រចម្រុះ ការទ្រទ្រង់ជីវភាពរស់នៅ ការប្រើប្រាស់ដីធ្លី ការធ្វើអាជីវកម្ម កសិកម្ម ព្រៃលិចទឹកជុំវិញតំបន់បឹងទន្លេសាប។ល។ ជារួមតាមការសិក្សា និងវិភាគបង្ហាញឱ្យឃើញពីភាពថយចុះ និងការ

គំរាមកំហែងឥតឈប់ឈរគួរឱ្យព្រួយបារម្ភមកលើធនធានជីកម្រក្នុងតំបន់បឹងទន្លេសាបនាពេលបច្ចុប្បន្ន និងពេលអនាគត ចំពោះសកម្មភាពអនាធិបតេយ្យ ដោយការធ្វើអាជីវកម្មហួសកម្រិតក្នុងការទាញយកអត្ថប្រយោជន៍ធនធានធម្មជាតិពី បឹងទន្លេសាប និងការទទួលរងនូវផលប៉ះពាល់ពីការអភិវឌ្ឍនូវហេដ្ឋារចនាសម្ព័ន្ធតំបន់មេគង្គលើ តំបន់បឹងទន្លេសាប និងលើផ្ទៃរងទឹកភ្លៀងតំបន់បឹងទន្លេសាប។



## ៤.១.៧ ការងារគ្រប់គ្រងសេវាកម្មបច្ចេកវិទ្យាព័ត៌មាន

### ក. ការងារគ្រប់គ្រងសេវាកម្មបច្ចេកវិទ្យាព័ត៌មាន



ព័ត៌មានទិន្នន័យ គឺជាធាតុចូលមួយដ៏សំខាន់ សម្រាប់បម្រើឱ្យស្ថាប័ន/អង្គភាពក្នុងការធ្វើការវិភាគ ដើម្បីរៀបចំឯកសារគោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងកម្មវិធី/គម្រោងនានា ជាពិសេសសម្រាប់បម្រើដល់អ្នកសិក្សាស្រាវជ្រាវ និងអ្នកធ្វើសេចក្តីសម្រេចចិត្តយកទៅប្រើប្រាស់ ជាមូលដ្ឋានក្នុងតម្រូវការផ្សេងៗ។ ការប្រមូលចងក្រង និងគ្រប់គ្រងព័ត៌មានទិន្នន័យពាក់ព័ន្ធតំបន់ទន្លេសាប ជាការងារអាទិភាពក្នុងចំណោមការងារអាទិភាពដទៃទៀត ដែលបានកំណត់នៅក្នុងតួនាទី និងភារកិច្ចទទួលខុសត្រូវរបស់អាជ្ញាធរទន្លេសាប តាមរយៈលទ្ធផលបានមកពីសកម្មភាពចុះសិក្សាស្រាវជ្រាវ និងសិក្សាស្វែងយល់ របស់ថ្នាក់ដឹកនាំ និងមន្ត្រីបច្ចេកទេសក្រោមឱវាទអគ្គលេខាធិការដ្ឋាន អាជ្ញាធរទន្លេសាប ។ ព័ត៌មាន ទិន្នន័យពាក់ព័ន្ធ តំបន់ទន្លេសាប ត្រូវបានសិក្សាស្រាវជ្រាវ និងប្រមូលផ្តុំទៅតាមគម្រោងសកម្មភាពនីមួយៗ ដែលបានលើកឡើងនៅក្នុង ផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពប្រចាំឆ្នាំរបស់អាជ្ញាធរទន្លេសាប ដើម្បីប្រមូលចងក្រង វិភាគ និងប្រឹក្សាយោបល់ជាមួយភាគីពាក់ព័ន្ធ សំដៅទៅរកការរៀបចំរបាយការណ៍បច្ចេកទេសសិក្សាស្រាវជ្រាវ កសាងផែនការយុទ្ធសាស្ត្រ កម្មវិធី/គម្រោង និងធ្វើការផ្សព្វផ្សាយ ចែករំលែកដល់អ្នកពាក់ព័ន្ធ ក្នុងការចូលរួមចំណែកដល់ការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍តំបន់ទន្លេសាបប្រកប ដោយនិរន្តរភាព។



អាជ្ញាធរទន្លេសាប បច្ចុប្បន្នបាននិងកំពុងតែគិតគូររៀបចំបរិវត្តកម្មប្រព័ន្ធគ្រប់គ្រងព័ត៌មានទិន្នន័យ (Data Server Management) ទាំងផ្នែករដ្ឋបាល បុគ្គលិក គណនេយ្យ និងកិច្ចការស្រាវជ្រាវ ឱ្យបានត្រឹមត្រូវស្របតាមបរិបទបច្ចេកវិទ្យាឌីជីថល ដែលនាយកដ្ឋាននីតិកម្ម និងផ្សព្វផ្សាយ ដើរតួនាទីជាឆ្អឹងខ្នង សម្រាប់ស្ថាប័នក្នុងការសម្របសម្រួលលើការប្រមូលផ្តុំ គ្រប់គ្រង និងចែករំលែកឱ្យមានប្រសិទ្ធភាព។

## ខ. ការងារគ្រប់គ្រង និងផ្សព្វផ្សាយព័ត៌មាន




ការគ្រប់គ្រង ផ្សព្វផ្សាយ និងចែករំលែកព័ត៌មាន ត្រូវបានកំណត់ជាសកម្មភាពអាទិភាព ក្នុងការជំរុញសកម្មភាពសិក្សាស្រាវជ្រាវឱ្យកាន់តែមានលក្ខណៈវិទ្យាសាស្ត្រ និងត្រូវបានដើរតួនាទីយ៉ាងសំខាន់ក្នុងការទទួលខុសត្រូវរបស់អាជ្ញាធរទន្លេសាប ដែលជាស្ថាប័នសិក្សាស្រាវជ្រាវ ប្រមូលចងក្រងរាល់ព័ត៌មាន ទិន្នន័យពាក់ព័ន្ធនឹងតំបន់ទន្លេសាប។ ការផ្សព្វផ្សាយ និងចែករំលែកនេះ គឺសកម្មភាពបញ្ច្រាបការយល់ដឹង ដល់អ្នកពាក់ព័ន្ធ និងបង្កើនកិច្ចសហប្រតិបត្តិការជាមួយដៃគូទាំងកម្រិតថ្នាក់ជាតិ ថ្នាក់មូលដ្ឋាន ថ្នាក់តំបន់ និងអន្តរជាតិ ដើម្បីចូលរួមចំណែកអនុវត្តដល់ការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍តំបន់ទន្លេសាប។

បច្ចុប្បន្ន នាយកដ្ឋាននីតិកម្ម និងផ្សព្វផ្សាយ នៃអគ្គលេខាធិការដ្ឋាន អាជ្ញាធរ ទន្លេសាប បាននិងកំពុងតែដំណើរការការផ្សព្វផ្សាយ និងចែករំលែក តាមរយៈនៃការបោះពុម្ពផ្សព្វផ្សាយឯកសារពាក់ព័ន្ធ ផលិតវីដេអូឯកសារ បង្ហាញពីសមិទ្ធផលនានា នៃសកម្មភាពការងាររបស់អាជ្ញាធរទន្លេសាប និងបានធ្វើការផ្សព្វផ្សាយ ចែករំលែកទៅដល់ក្រសួង-ស្ថាប័ន ដៃគូពាក់ព័ន្ធ និងសហគមន៍មូលដ្ឋាននៅ ជុំវិញតំបន់បឹងទន្លេសាប និងនៅលើប្រព័ន្ធបណ្តាញទំនាក់ទំនងអ៊ីនធើណេត (Website, Facebook, Telegram Channel, Youtube Channel,Twitter)។ អាជ្ញាធរទន្លេសាប ក៏បាននិងកំពុងតែគិតគូររៀបចំបរិវត្តកម្មផងដែរ ទៅលើការគ្រប់គ្រងប្រសិទ្ធភាពនៃប្រព័ន្ធបណ្តាញផ្សព្វផ្សាយ និងចែករំលែកព័ត៌មាន ចំណេះដឹង ឱ្យបានដល់អ្នកប្រើប្រាស់ ឬក្រុមគោលដៅក្នុងការទទួលបាននូវភាពងាយស្រួល ជាពិសេសបាននិងកំពុងតែរៀបចំកសាងនូវផែនការប្រាស្រ័យទាក់ទង ដើម្បីពង្រីកសកម្មភាពសេវាកម្មបច្ចេកវិទ្យាព័ត៌មាន។



## ៤.២ ការខារចំពោះមុខ

### ៤.២.១ ការខារបច្ចុប្បន្នភាពផែនទី និងការបោះបង្គោលព្រំតំបន់៣



បន្ទាប់ពីទទួលបាននូវអនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់របស់សម្ដេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នាឱកាស សន្និបាតបូកសរុបការងាររបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងសជណ លេខ ១៨៨ ចុះថ្ងៃទី ៩ ខែកុម្ភៈ ឆ្នាំ២០២៤ របស់ទីស្ដីការគណៈរដ្ឋមន្ត្រី អាជ្ញាធរទន្លេសាបបានអនុវត្តនូវការងារចំពោះមុខមានៈ

#### ក. មូលដ្ឋាននៃការប្រមូលទិន្នន័យ

ក្រុមការងារបច្ចេកទេស តំណាងអាជ្ញាធរទន្លេសាប ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានជួបពិគ្រោះយោបល់ដើម្បីពិនិត្យផ្ទៀងផ្ទាត់ទិន្នន័យ លើអនុក្រឹត្យសរុបចំនួន ១៦ សេចក្ដីជូនដំណឹងសរុបចំនួន ១៣ និងទិន្នន័យភូមិសាស្ត្រ(Shapefile) ដែលបានកាត់ឆ្វៀលសម្រាប់ធ្វើជាមូលដ្ឋានរៀបចំផែនទីកំណត់តំបន់៣ តំបន់២ និងតំបន់១ (ថ្មី) ស្ថិតនៅក្នុងខេត្តទាំង ៦ ជុំវិញបឹងទន្លេសាប។






| ខេត្ត | អនុក្រឹត្យ | សជណ |
|---|---|---|
| កំពង់ឆ្នាំង | 3 (១១២ , ២៤ , ២៦) | 2 (៤១៦ , ៥៣) |
| ពោធិ៍សាត់ | 2 (១០១ , ៤៣) | 2 (៣៩២ , ១៦៧) |
| បាត់ដំបង | 3 (១១០ , ៩០ , ៩១) | 3 (៤១៣ , ៥០៦ , ៤៦៨) |
| បន្ទាយមានជ័យ | 3 (១០៦ , ៥៧ , ៥៨) | 2 (៤០២ , ២៦៨) |
| សៀមរាប | 2 (៨៨ , ៨៩) | 1 (៤៦២) |
| កំពង់ធំ | 3 (១០៥ , ២៨ , ២៩) | 3 (២២៤, ៣៩៣ , ៧៧) |
| សរុប | 16 អនុក្រឹត្យ | 13 សជណ |

ចំណុចនិយាមការបង្គោលតំបន់៣ ចំនួន ១ ២២៤បង្គោល

| ឈ្មោះខេត្ត | បង្គោលតំបន់បឹងទន្លេសាប តំបន់២ | បង្គោលតំបន់បឹងទន្លេសាប តំបន់៣ | ការផ្ទៀងផ្ទាត់ |
|---|---|---|---|
| កំពង់ឆ្នាំង | ៤០៨ | ២១៥ | ២១៥ |
| ពោធិ៍សាត់ | ១១២ | ១៤៦ | ១៤៦ |
| បាត់ដំបង | ២៧៣ | ១៧១ | ១៧១ |
| បន្ទាយមានជ័យ | ៥១ | ៤៧ | ៤៧ |
| សៀមរាប | ៤៧២ | ២៩៩ | ២៩៩ |
| កំពង់ធំ | ៥៨៤ | ៣៤៦ | ៣៤៦ |
| សរុបរួម | ១ ៩០០ | ១ ២២៤ | ១ ២២៤ |



### ខ. ការងារសាងសង់បង្គោលព្រំតំបន់៣



បន្ទាប់ពីទទួលបាននូវគោលការណ៍ឯកភាពពីរាជរដ្ឋាភិបាល ក្នុងការសង់បង្គោលព្រំតំបន់៣ឡើងវិញ និងការដឹកនាំចង្អុលបង្ហាញ ដ៏ខ្ពង់ខ្ពស់ពីឯកឧត្តម **ថោ ជេដ្ឋា** រដ្ឋមន្ត្រីក្រសួងធនធានទឹកនិងឧតុនិយម និងជាប្រធានអាជ្ញាធរទន្លេសាប ក្រុមការងារ បច្ចេកទេសអាជ្ញាធរទន្លេសាប បានសហការជាមួយក្រសួង-ស្ថាប័ន អាជ្ញាធរដែនដីពាក់ព័ន្ធចុះកំណត់និយាមកា និងសាងសង់បង្គោលព្រំតំបន់៣ រួចរាល់សរុបចំនួន ១២២៤ បង្គោល។



សកម្មភាពមន្ត្រីបច្ចេកទេសអាជ្ញាធរទន្លេសាបចុះពិនិត្យនិងផ្ទៀងផ្ទាត់ភាពត្រឹមត្រូវនៃនិយាមកា ចំណុចបង្គោលព្រំកំណត់តំបន់៣ ក្នុងភូមិសាស្ត្រខេត្តទាំង៦ ជុំវិញបឹងទន្លេសាប



សកម្មភាពមន្ត្រីបច្ចេកទេសអាជ្ញាធរទន្លេសាបចុះពិនិត្យ មើលទីតាំងសាងសង់ដោយធ្វើការផ្ទៀងផ្ទាត់និយាមកាដែលក្រុមបច្ចេកទេសបានកំណត់ ពិនិត្យការដ្ឋានសាងសង់បង្គោល ពិនិត្យតាមដានលក្ខណៈបច្ចេកទេស គុណភាពសំណង់ និងគំរូប្លង់ និងផ្តល់ការណែនាំបច្ចេកទេសសំណង់ដល់អ្នកទទួលសាងសង់បង្គោលទៅតាមកិច្ចសន្យាការងារ។



សកម្មភាពថ្នាក់ដឹកនាំអាជ្ញាធរទន្លេសាប និងប្រតិភូក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចុះពិនិត្យ និងវាយតម្លៃប្រគល់ទទួលបង្គោលកំណត់ព្រំតំបន់ ៣ នៃបឹងទន្លេសាប

### គ. ការងារអធិការកិច្ចដែនព្រៃលិចទឹក និងព្រៃលិចទឹក

អាជ្ញាធរទន្លេសាប បានដឹកនាំក្រុមការងារចុះពិនិត្យតាមដាន និងអធិការកិច្ចដែនព្រៃលិចទឹក និងព្រៃលិចទឹក តាមមុខព្រួញផ្លូវជាតិលេខ៥ និងផ្លូវជាតិលេខ៦ ដើម្បីតាមដានត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ និយាមកាបង្គោលព្រំការពារដែនព្រៃលិចទឹក និងព្រៃលិចទឹក តាមស្មារតីអនុក្រឹត្យលេខ១៩៧ អនក្រ.បក ក្នុងខេត្តទាំង ៦ ជុំវិញបឹងទន្លេសាប ដោយមានកិច្ចចូលរួមសហការពីស្ថាប័ន មន្ទីរជំនាញជុំវិញខេត្ត អាជ្ញាធរដែនដីពាក់ព័ន្ធតំបន់បឹងទន្លេសាប លើកិច្ចការការពារធនធានធម្មជាតិ ពិសេសព្រៃលិចទឹក និងដែនព្រៃលិចទឹកនៅជុំវិញបឹងទន្លេសាប និងតំបន់ពាក់ព័ន្ធប្រកបដោយប្រសិទ្ធភាពខ្ពស់ ព្រមទាំងពិនិត្យ ជួសជុល ថែទាំ ឬដាំបង្គោលព្រំតំបន់៣ និងស្លាកសញ្ញាការពារដែនព្រៃលិចទឹក និងព្រៃលិចទឹក។






សកម្មភាពក្រុមការងារអាជ្ញាធរទន្លេសាប ចុះពិនិត្យតាមដាន និងអធិការកិច្ចដែនព្រៃលិចទឹក និងព្រៃលិចទឹក (មុខព្រួញផ្លូវជាតិលេខ៦)






សកម្មភាពក្រុមការងារអាជ្ញាធរទន្លេសាប ចុះពិនិត្យតាមដាន និងអធិការកិច្ចដែនព្រៃលិចទឹក និងព្រៃលិចទឹក (មុខព្រួញផ្លូវជាតិលេខ៥)

### ឃ. ការងារផ្សព្វផ្សាយច្បាប់បទដ្ឋានគតិយុត្តពាក់ព័ន្ធកិច្ចការពារព្រៃលិចទឹក




អាជ្ញាធរទន្លេសាប បានដឹកនាំក្រុមការងារទទួលបន្ទុកផ្សព្វផ្សាយច្បាប់ បទដ្ឋានគតិយុត្ត ពាក់ព័ន្ធការចុះបោះបង្គោលកំណត់ព្រំតំបន់៣ នៃដែនព្រៃលិចទឹក នៃអាជ្ញាធរទន្លេសាប បានចុះប្រជុំផ្សព្វផ្សាយផ្តោតសំខាន់លើច្បាប់ បទដ្ឋានគតិយុត្ត ព័ត៌មាន និងចំណេះដឹងពាក់ព័ន្ធនឹងការចុះបោះបង្គោលកំណត់ព្រំតំបន់៣ នៃដែនព្រៃលិចទឹក និងព្រៃលិចទឹកស្ថិតនៅក្នុងខេត្តទាំង ៦ ជុំវិញបឹងទន្លេសាប ទៅកាន់ស្ថាប័នជំនាញពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋាន ភូមិ/ឃុំ/ស្រុក ដែលពាក់ព័ន្ធនឹងតំបន់៣ ក្នុងការផ្តល់កិច្ចសហការ និងចូលរួមអនុវត្តដើម្បីទទួលបានប្រសិទ្ធភាពខ្ពស់។






### ៤.៣ ការវិភាគមុខងារ និងរចនាសម្ព័ន្ធស្ថាប័ន





- ថ្នាក់ដឹកនាំអាជ្ញាធរទន្លេសាប បានចូលរួមកិច្ចប្រជុំលើការវិភាគមុខងារ និងរចនាសម្ព័ន្ធរបស់ស្ថាប័ន ផ្ទៃក្នុងអង្គភាព ជាមួយក្រសួងធនធានទឹកនិងឧតុនិយម ក្រសួងមុខងារសាធារណៈ និងក្រុមប្រឹក្សាអ្នកច្បាប់របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- បានប្រជុំពិគ្រោះ និងប្រឹក្សាយោបល់ជាមួយក្រុមប្រឹក្សាអ្នកច្បាប់របស់ទីស្តីការគណៈរដ្ឋមន្ត្រី មេធាវីនិងក្រុមប្រឹក្សាអ្នកច្បាប់អមក្រសួងធនធានទឹក និងឧតុនិយម អាជ្ញាធរទន្លេសាប បានទទួលលិខិតលេខ ៧៨០ សជណ.កបច ចុះថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ២០២៤ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ស្តីពីការផ្ទេរលេខាធិការដ្ឋានបបនីយជីវមណ្ឌលបឹងទន្លេសាប ពីគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជាទៅស្ថិតក្រោមការគ្រប់គ្រងរបស់អាជ្ញាធរទន្លេសាប និងបានរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋានអាជ្ញាធរទន្លេសាប។







## ៥. បញ្ហាប្រឈម

- សមត្ថភាព និងការយល់ដឹងមន្ត្រីលើកិច្ចការបច្ចេកទេស នៅមានកម្រិតក្នុងការអនុវត្តការងារជាក់ស្តែង
- មន្ត្រីបម្រើការងារតាមនាយកដ្ឋាន និងការិយាល័យមួយចំនួនមានចំនួនតិច និងមិនទាន់សមស្របតាមជំនាញ
- នីតិវិធីនៃការវិភាគមុខងារ និងរចនាសម្ព័ន្ធថ្មី នៅមានការជជែក ពិភាក្សាបន្ត
- ថវិកា និងធនធានមនុស្ស មិនទាន់ឆ្លើយតបនឹងទំហំការងារស្មុគ និងចំពោះមុខ
- សម្ភារៈឧបករណ៍បច្ចេកទេសស្រាវជ្រាវ និងទំនាក់ទំនងព័ត៌មានបែបលក្ខណៈវិទ្យាសាស្ត្រ មិនទាន់ឆ្លើយតបនឹងបរិវត្តកម្មឌីជីថល
- ការផ្តល់កិច្ចសហការ និងចែករំលែកព័ត៌មាន-ទិន្នន័យ ពីបណ្តាក្រសួង-ស្ថាប័នពាក់ព័ន្ធទាំងកម្រិតថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិនៅមានកម្រិត
- ទីស្នាក់ការ/អង្គភាព និងមន្ត្រីបង្គោលអាជ្ញាធរទន្លេសាប នៅថ្នាក់ក្រោមជាតិនៃខេត្តទាំង៨ ជុំវិញតំបន់ទន្លេសាប មិនទាន់បានរៀបរយនៅឡើយ។

## ៦. សន្និដ្ឋាន និងទិសដៅការងារបន្ត

ផ្អែកលើសមិទ្ធផលនៃការអនុវត្តផែនការសកម្មភាពប្រចាំឆ្នាំ២០២៤ និងផែនការយុទ្ធសាស្ត្ររបស់អាជ្ញាធរទន្លេសាប ២០២៤-២០២៨ កន្លងមក អាជ្ញាធរទន្លេសាប បានធ្វើការវាយតម្លៃដោយយកចិត្តទុកដាក់បំផុតលើភាពខ្លាំង និងបញ្ហាប្រឈម ដែលតម្រូវឱ្យបន្តដោះស្រាយដោយភាពហ្មត់ចត់ នៅដំណាក់កាលបន្ទាប់ក្នុងការរៀបចំ និងអនុវត្តផែនការយុទ្ធសាស្ត្រ សម្រាប់អាជ្ញាធរទន្លេសាប និងផែនការសកម្មភាពប្រចាំឆ្នាំ២០២៥ របស់អាជ្ញាធរទន្លេសាប ដើម្បីអនុលោមតាមស្មារតីនៃបេសកកម្មការងារក្នុងការសម្របសម្រួល ដល់ការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍តំបន់ទន្លេសាបប្រកបដោយចីរភាព។ ជាពិសេសចូលរួមលើកកម្ពស់ប្រសិទ្ធភាពការអនុវត្ត យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាលក្នុងនីតិកាលទី៧ នៃរដ្ឋសភា ដើម្បី កំណើន ការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព សំដៅការពារ ថែរក្សា និងពូនជ្រុំសមិទ្ធផលជាតិ លើកកម្ពស់កិត្យានុភាពជាតិឱ្យខ្ពស់ត្រដែត ជំរុញសន្ទុះនៃកំណើនសេដ្ឋកិច្ច និងកសាងមូលដ្ឋានគ្រឹះឆ្ពោះទៅសម្រេចបានចក្ខុវិស័យកម្ពុជាឆ្នាំ ២០៥០។

ក្នុងស្មារតីនេះ អាជ្ញាធរទន្លេសាប រៀបចំកសាង និងដាក់ចេញនូវផែនការសកម្មភាពប្រចាំឆ្នាំ២០២៥ និងផែនការ យុទ្ធសាស្ត្ររយៈពេល ៥ឆ្នាំ (២០២៤-២០២៨) ដោយយោងលើកត្តាចាំបាច់ក្នុងបរិយាកាសសំខាន់ៗ ដូចខាងក្រោម ៖

**១.** ការបន្តពង្រឹង និងពង្រីកសមិទ្ធផលការងារ ដែលអាជ្ញាធរទន្លេសាប សម្រេចបាននៅក្នុងដំណាក់កាលកន្លងមក នៅក្នុងក្របខ័ណ្ឌបេសកកម្មការងារដូចបានកំណត់ក្នុងបទដ្ឋានគតិយុត្ត និងដំណើរការអនុវត្តផែនការសកម្មភាពប្រចាំឆ្នាំ និងផែនការយុទ្ធសាស្ត្រសម្រាប់អាជ្ញាធរទន្លេសាប។

**២.** ការបន្តកែលម្អ និងអភិបាលកិច្ចការងាររបស់អង្គភាព ឱ្យសម្រេចបាននូវប្រព័ន្ធគ្រប់គ្រងការងារប្រកប ដោយប្រសិទ្ធភាពនៅក្នុងទិដ្ឋភាពសុខដុមនីយកម្មផ្ទៃក្នុងការងារ និងកិច្ចសហប្រតិបត្តិការ បណ្តាដៃគូខាងក្រៅ ទាំងការដឹកនាំការសម្របសម្រួល ការត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តការងារប្រចាំថ្ងៃ គោលនយោបាយ និងយុទ្ធសាស្ត្រនានា។

**៣.** ការបន្តកសាង និងពង្រឹងមូលដ្ឋានដ៏រឹងមាំរបស់អាជ្ញាធរទន្លេសាប ក្នុងការយកចិត្តទុកដាក់ ជំរុញការលើកទឹកចិត្ត និងពង្រឹងការកសាងធនធានមនុស្សឱ្យបានគ្រប់ជ្រុងជ្រោយ តាមរយៈការគិតគូរដល់មន្ត្រីបន្តវេន និងកសាងសមត្ថភាពចំណេះដឹងជំនាញ លើកិច្ចការសិក្សាស្រាវជ្រាវ ការធ្វើវិភាគ ពិសោធន៍ ការរៀបចំចងក្រងសរសេររបាយការណ៍បច្ចេកទេស ការគ្រប់គ្រងព័ត៌មានទិន្នន័យ ការប្រាស្រ័យទាក់ទង ការតាមដាន និងវាយតម្លៃលើវឌ្ឍនភាពនៃដំណើរការការងារ និងការអនុវត្តកម្មវិធី/គម្រោង ផែនការយុទ្ធសាស្ត្រ និងគោលនយោបាយរបស់អង្គភាព ដើម្បីបន្តការកែលម្អឱ្យបានកាន់តែប្រសើរឡើង ស្របតាមបរិការណ៍សង្គមឌីជីថល។

**៤.** ការបន្តពង្រឹងអនុវត្តការសិក្សាស្រាវជ្រាវ និងសិក្សាស្វែងយល់ពីព័ត៌មាន ទិន្នន័យដែលមាន លក្ខណៈវិទ្យាសាស្ត្រស្របតាមបរិបទបច្ចេកវិទ្យាថ្មីសង្គមឌីជីថល ដើម្បីធ្វើជាមូលដ្ឋានដ៏រឹងមាំសម្រាប់ធ្វើការវិភាគក្នុងការរៀបចំកសាងឯកសារបច្ចេកទេស កម្មវិធី/គម្រោងសកម្មភាព គោលនយោបាយ ផែនការ យុទ្ធសាស្ត្រពាក់ព័ន្ធ ដែលជាអាទិភាពការងារស្នូលរបស់អាជ្ញាធរទន្លេសាប រួមមាន៖ របាយការណ៍ ស្ថានភាពអាងបឹងទន្លេសាប ការរៀបចំផែនទីតំបន់ទន្លេសាប គោលនយោបាយ/ផែនការយុទ្ធសាស្ត្រគ្រប់គ្រង និងអភិវឌ្ឍន៍តំបន់បឹងទន្លេសាប ការគ្រប់គ្រងធនធានទឹកចម្រុះអាងបឹងទន្លេសាប និងផែនការចង្អុល/ផែនការមេសម្រាប់ការគ្រប់គ្រង និងអភិវឌ្ឍន៍តំបន់បឹងទន្លេសាប យុទ្ធសាស្ត្រគ្រប់គ្រងសហគមន៍តំបន់បឹងទន្លេសាប បន្សាំជាមួយបម្រែបម្រួលអាកាសធាតុ សម្រាប់ជំរុញប្រសិទ្ធភាពដល់ការសម្របសម្រួល និងលើកកម្ពស់ប្រសិទ្ធភាពនៃកិច្ច

សហប្រតិបត្តិការទាំងថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ សហគមន៍មូលដ្ឋាន អង្គការមិនមែនរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងម្ចាស់ជំនួយក្នុងតំបន់ និងអន្តរជាតិ ដើម្បីចូលរួមលើកកម្ពស់ដល់ការគ្រប់គ្រងធនធានធម្មជាតិ បរិស្ថាន និងអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមតំបន់បឹងទន្លេសាប ប្រកបដោយចីរភាព។

**៥.** ការបន្តលើកកម្ពស់ប្រសិទ្ធភាពការងារប្រព័ន្ធគ្រប់គ្រងព័ត៌មាន ទិន្នន័យ បណ្ដាញផ្សព្វផ្សាយ និងចែករំលែកព័ត៌មានចំណេះដឹងឱ្យបានកាន់តែខ្លាំងក្លា តាមរយៈនៃការពង្រឹងការយកចិត្តទុកដាក់ហេដ្ឋារចនាសម្ព័ន្ធព័ត៌មាន ការប្រាស្រ័យទាក់ទង និងបច្ចេកវិទ្យា ដើម្បីលើកកម្ពស់ប្រសិទ្ធភាពការងារស្នូលរបស់អង្គភាពឱ្យកាន់តែមានភាពរឹងមាំ ស្របនឹងបច្ចេកវិទ្យាថ្មីៗក្នុងសង្គមឌីជីថល។

**៦.** ការបន្តពង្រឹងភាពជាដៃគូ និងជំរុញកិច្ចសហប្រតិបត្តិការទាំងក្នុងកម្រិតជាតិ តំបន់ និងអន្តរជាតិ ដើម្បីកៀរគរជំនួយបច្ចេកទេស និងហិរញ្ញវត្ថុ ក្នុងការចូលរួមលើកកម្ពស់អភិបាលកិច្ចដំណើរការការងារ និងចូលរួមគាំទ្រការគ្រប់គ្រងធនធានធម្មជាតិ បរិស្ថាន និងការអភិវឌ្ឍនសេដ្ឋកិច្ចសង្គមតំបន់បឹងទន្លេសាបប្រកបដោយចីរភាព។

ក្នុងស្មារតីបន្តរៀបចំ និងអនុវត្តនូវផែនការសកម្មភាពប្រចាំឆ្នាំ ២០២៥ នេះ។ អាជ្ញាធរទន្លេសាប បានសម្លឹងឃើញនូវគោលបំណង និងកម្មវត្ថុច្បាស់លាស់ ក្នុងការជំរុញកិច្ចការស្នូលរបស់អង្គភាព ដើម្បីលើកកម្ពស់ប្រសិទ្ធភាពការអនុវត្ត យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី ១ របស់រាជរដ្ឋាភិបាល នីតិកាលទី៧ ដើម្បីកំណើន ការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព សំដៅការពារ ថែរក្សា និងពូនជ្រុំសមិទ្ធផលជាតិ លើកកម្ពស់កិត្យានុភាពជាតិឱ្យខ្ពស់ត្រដែត ជំរុញសន្ទុះនៃកំណើនសេដ្ឋកិច្ច និងកសាងមូលដ្ឋានគ្រឹះឆ្ពោះទៅសម្រេចបាន ចក្ខុវិស័យកម្ពុជាឆ្នាំ ២០៥០។

កត្តានៃការសម្លឹងឆ្ពោះទៅអនាគតរបស់ អាជ្ញាធរទន្លេសាប រួមមាន ៖

**១.** អាជ្ញាធរទន្លេសាប ជាអង្គភាពប្រមូលផ្តុំ ឬកន្លែងផ្ទុកដោយព័ត៌មាន ទិន្នន័យពាក់ព័ន្ធនឹងតំបន់បឹងទន្លេសាប (Tonle Sap Information/Data Bank) ប្រកបដោយលក្ខណៈវិទ្យាសាស្ត្រ និងអាចទុកចិត្តបាន សម្រាប់អ្នកស្រាវជ្រាវ អ្នកធ្វើសេចក្តីសម្រេចចិត្ត និងអ្នករៀបចំគោលនយោបាយ យកទៅប្រើប្រាស់ និងវិភាគតាមតម្រូវការ។

**២.** អាជ្ញាធរទន្លេសាប ជាអង្គភាព ប្រមូលផ្តុំ ពូនជ្រុំនូវធនធានមនុស្ស ដែលប្រកបដោយចំណេះដឹង និងជំនាញច្បាស់លាស់ លើការសិក្សាស្រាវជ្រាវ និងវិភាគមានលក្ខណៈវិទ្យាសាស្ត្រ ដែលមានការវិវត្តន៍ទៅតាមបរិបទសង្គមឌីជីថល ដើម្បីជួយលើកកម្ពស់ប្រសិទ្ធភាពការងារក្នុងអង្គភាព និងសង្គមជាតិ។

**៣.** អាជ្ញាធរទន្លេសាប ជាអង្គភាព ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ និងប្រកបដោយគុណតម្លៃ ដែលជាសេនាធិការផ្ទាល់ឱ្យរាជរដ្ឋាភិបាល ក្នុងការគិតគូរដោយហ្មត់ចត់លើការរក្សាបាននូវតុល្យភាពនៃការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានធម្មជាតិតំបន់បឹងទន្លេសាបប្រកបដោយនិរន្តរភាព ហើយក៏នឹងក្លាយជាដៃគូដ៏សំខាន់ជាមួយក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល និងដៃគូពាក់ព័ន្ធទាំងកម្រិតជាតិ តំបន់ និងអន្តរជាតិ។

**៤.** អាជ្ញាធរទន្លេសាប ជាអង្គភាព ប្រកបដោយឧត្តមភាពការងារក្នុងការសម្របសម្រួលដល់ការគ្រប់គ្រងធនធានទឹក បរិស្ថាន និងធនធានធម្មជាតិក្នុងតំបន់អាង/បឹងទន្លេសាប ស្របតាមគោលការណ៍ដែលបានកំណត់ក្នុងក្របខ័ណ្ឌអភិក្រមគ្រប់គ្រងអាងទន្លេ (River Basin Management Approach) និងក្លាយជាដៃគូយ៉ាងជិតស្និទ្ធជាមួយបណ្តាប្រទេសដែលជាសមាជិកអង្គការអាងទន្លេ (River Basin Organization)។

Website: https://tonlesap.gov.kh

Facebook: https://www.facebook.com/TSA.MOWRAM

Telegram: https://t.me/TonleSap_Authority

YOUTUBE: https://www.youtube.com/@TonleSapAuthority

Twitter: https://twitter.com/tonle_sap